ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា

THE IMPORTANCE OF HIGHER EDUCATION DSTASTNCE LEARNING

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តម

# THE IMPORTANCE OF HIGHER EDUCATION DSTASTNCE LEARNING

សាស្ត្រាចារ្យណែនាំ ៖  ឯក វ៉ាន់ឌុន

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២១**
**ប្រធានបទ៖ សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ក វុធ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និង
ជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

សាស្ត្រាចារ្យណែនាំ

ឯក វ៉ាន់ឌុន

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

(Impression)

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំ សិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំ យល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់ផងដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុង នោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយ ឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខ ជំនាញសំខាន់ៗដែលពាក់ព័ន្ធ នឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំ សិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុ វត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ នឹងត្រួតពិនិត្យ វាយតម្លៃព្រមទាំង ផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យ ឆ្លើយតបឱ្យបានល្អប្រសើរ នឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើង ខ្ញុំបានសង្កេតឃើញថា កិច្ចការងារមួយនេះពិតជាមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបធ្វើឱ្យក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសយកនូវប្រធានបទមួយស្តីអំពី **“សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា”** យកមកធ្វើការសិក្សាស្រាវជ្រាវ នឹងចងក្រងក្នុងគោល បំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា។ ក្រុមយើងខ្ញុំសង្ឃឹមថា ការ រៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នក ស្រាវជ្រាវ ដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង នឹងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនិង ទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ជូ តាំងយី**

ID: B21/1317



**ឡឿត សំណាង**

ID: B21/3484



**ឈឿន ផាត្តនា**

ID: B21/851



**ឈន វ៉ាន់ឆាយ**

ID: B21/3485

# សេចក្ដីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យ **សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្ដល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្ដុះបណ្ដាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្ដល់ទីកន្លែងបណ្ដុះបណ្ដាល ព្រមទាំងផ្ដល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ឯក វ៉ាន់ឌុន** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**អំណះអំណាង**

ក្រុមខ្ញុំបាទ នាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមជានាអះអាងថា ខ្លឹមសារសារណាក្រុមយើងខ្ញុំដែលបានលើកយកមកបកស្រាយក្រោមប្រធានបទ "សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា" នេះ គឺជាស្នាដៃរបស់ក្រុម នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធ នឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. .............. ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្នុងរយៈពេលជាងពីរទសវត្សន៍ចុងក្រោយនេះ ស្ថិតនៅក្រោមដំបូលនៃសន្តិភាព និងស្ថិរភាពពេញលេញ រាជរដ្ឋាភិបាលបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រចតុកោណ និងកម្មវិធីកែទម្រង់សំខាន់ៗ ព្រមទាំងបានបង្កើនចំណាយសាធារណៈយ៉ាងច្រើនសំដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសវិស័យអប់រំ និងសង្គមជាតិទាំងមូល។ ជាលទ្ធផលកម្ពុជា សម្រេចបានកំណើនខ្ពស់ដែលបានចូលរួមយ៉ាងខ្លាំងខ្លាគួរជាទីមោទនៈក្នុងការបង្កើត ការងារ និងការកាត់បន្ថយអត្រានៃភាពក្រីក្រជាពិសេសការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ យ៉ាងណាមិញក្នុងឆ្នាំ ២០២៣ មានភាពរីកចម្រើនយ៉ាងខ្លាំងខាងការអប់រំតាមប្រព័ន្ធឌីជីថល ឬការសិក្សាពីចម្ងាយដែលជួយដល់វិស័យអប់រំ ឱ្យកាន់តែមានភាពងាយស្រួលជាមុន។

អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការសិក្សាពីចម្ងាយមានការកើនឡើងជាលំដាប់ ប៉ុន្តែនៅក្នុងការសិក្សាពីចម្ងាយនេះ ផងដែរក៏មានផលលំបាកដល់សិស្សនិស្សិតភាគច្រើនពិបាកប្រើប្រាស់ទៅលើបច្ចេកវិទ្យាទំនើបៗដែលជាកត្តាសំខាន់ក្នុងការរៀនសូត្រ។ ក្នុងការសិក្សាពីចម្ងាយនេះ ទាមទារឱ្យសិស្សចេះប្រើប្រាស់នូវប្រព័ន្ធសិក្សាដែលបានបង្កើតមកថ្មីៗថែមទៀតផង។

ជាការពិតណាស់វិស័យអប់រំនៅកម្ពុជា នឹងមានភាពកើនឡើងជាលំដាប់ព្រោះមានការសិក្សាតាមបែបថ្មីៗ ជាពិសេសការសិក្សាពីចម្ងាយដែលពេញនិយមនាពេលបច្ចុប្បន្ននេះ។ ព្រោះការសិក្សាបែបនេះធ្វើឱ្យសិស្សនិស្សិតចំណាយពេលវេលាតិច ប៉ុន្តែទទួលបាននូវចំណេះដឹងពេញលេញថែមទៀតផង។ ក្រៅពីនេះការសិក្សាពីចម្ងាយផ្តល់ឱ្យសិស្សនិស្សិត ចំណេញថវិកា ចេះគ្រប់គ្រងខ្លួនឯងឱ្យមានវិន័យ កាត់បន្ថយហានិភ័យនៃការឆ្លងជំងឺផ្សេងៗ ពង្រីកចំណេះដឹងថ្មីៗ ធ្វើឱ្យប្រសើរឡើងនូវអក្ខរកម្មឌីជីថល ថែមទាំងចូលរួមលើកកម្ពស់លើវិស័យបច្ចេកវិទ្យា។ លើសពីនេះ ធ្វើឱ្យនិស្សិតគ្រប់រូបត្រូវចេះប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនេះហើយក៏ជាភាពងាយស្រួលដល់ការសិក្សាបានច្រើនជាងមុនដែល ធ្វើឱ្យនិស្សិតចេះប្រើយ៉ាងស្ទាត់ជំនាញលើបច្ចេកវិទ្យាទាំងនេះជាពិសេសជួយអភិវឌ្ឍដល់វិស័យបច្ចេកវិទ្យានិងការសិក្សាពីចម្ងាយឱ្យកាន់តែមានភាពរីកចម្រើនជាលំដាប់។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

**ជំពូកទី១**
**សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.មូលហេតុ អ្វីខ្លះដែលបណ្តាលឱ្យមានការសិក្សាពីចម្ងាយ? ........ ២
២.តើការសិក្សាពីចម្ងាយផ្តល់សារៈសំខាន់អ្វីខ្លះ? ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
១.៥.១ ការប្រមូលទិន្នន័យដំបូង ........ ៣
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី២**
**សារៈសំខាន់នៃការសិក្សាពីចម្ងាយ**

២.១ លក្ខណៈទូទៅនៃសារៈសំខាន់អំពីការសិក្សា ........ ៥
២.១.១ និយមន័យ ........ ៥
២.១.២ ប្រវត្តិនៃការសិក្សា ........ ៥
២.១.៣ ទ្រឹស្តីនៃការសិក្សា ........ ៦
២.២ មូលហេតុដែលបណ្តាលឱ្យមានការសិក្សា ........ ៧
២.២.១ និយមន័យ ........ ៧
២.២.២ ប្រព័ន្ធអប់រំនៃការសិក្សា ........ ៧
២.២.៣ ទ្រឹស្តីនៃយុទ្ធសាស្ត្រការសិក្សា ........ ៧

២.៣ សារៈសំខាន់នៃការសិក្សាពីចម្ងាយ ..................................................................................... ៨
២.៣.១ និយមន័យសារៈសំខាន់ ..................................................................................... ៨

## ជំពូកទី៣
## សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា

៣.១ ស្ថានភាពទូទៅនៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា ..................................... ៩
៣.១.១ ប្រវត្តិរបស់នៃការសិក្សាពីចម្ងាយ ..................................................................... ៩
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ នៃក្រសួងអប់រំយុវជន និងកីឡា ........................ ១០
ក.ចក្ខុវិស័យ ..................................................................................................... ១០
ខ.បេសកកម្ម ..................................................................................................... ១១
គ.គោលដៅ ..................................................................................................... ១២
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច ....................................................... ១៦
ក. រចនាសម្ព័ន្ធគ្រប់គ្រង ..................................................................................... ១៦
ខ. តួនាទីគណគ្រប់គ្រង ..................................................................................... ១៦
គ. ភារកិច្ចគណគ្រប់គ្រង ..................................................................................... ១៨
៣.២ មូលហេតុដែលបណ្តាលឱ្យមានការសិក្សាពីចម្ងាយ ............................................... ២០
៣.២.១ គ្រួសារ ..................................................................................................... ២១
៣.២.២ មធ្យោបាយ ឬយាន្តជំនិះ ..................................................................................... ២១
៣.២.៣ ខ្លួនឯង ..................................................................................................... ២១
៣.២.៤ ផ្ទះនៅឆ្ងាយពីសាលា ..................................................................................... ២១
៣.២.៥ បញ្ហាផ្សេងៗ ..................................................................................................... ២១
៣.២.៦ សុវត្ថិភាពជាចម្បង ..................................................................................... ២១
៣.៣ សារៈសំខាន់នៃការកាសិក្សាពីចម្ងាយ ..................................................................... ២២
៣.៣.១ លទ្ធភាពសមរម្យ ..................................................................................... ២២
៣.៣.២ ចំណេញពេលវេលា ..................................................................................... ២២
៣.៣.៣ ចំណេញទីកន្លែងសិក្សា ..................................................................................... ២២
៣.៣.៤ កាត់បន្ថយហានិភ័យនៃការឆ្លងជំងឺផ្សេងៗ ..................................................... ២៣
៣.៣.៥ ពង្រីកចំណេះដឹងថ្មីៗ ..................................................................................... ២៣
៣.៣.៦ ការសហការគ្នាក្នុងការរៀនសូត្រ ..................................................................... ២៣
៣.៣.៧ ធ្វើឱ្យប្រសើរឡើងនូវអក្ខរកម្មឌីជីថល ..................................................................... ២៣
៣.៣.៨ ចូលរួមលើកកម្ពស់លើវិស័យបច្ចេកវិទ្យា ..................................................................... ២៣
៣.៣.៩ កាត់បន្ថយពេលវេលាពីការស្វះចរាចរណ៍ ..................................................................... ២៣

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........................................ ២៤
៤.២ ការវិភាគលើចំណុចខ្សោយ ........................................ ២៥

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................ ២៦
៥.២ ការផ្តល់អនុសាសន៍ ........................................ ២៦

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ សំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើបណ្តាប្រទេសទាំងមូលក្នុងនោះ ប្រទេសកម្ពុជាបានជួបនៅវិបត្តិសង្គ្រាមយ៉ាងពុំរ៉ៃដែលបន្លាយពេលជាច្រើនខែឆ្នាំ ដែលជាហេតុប៉ះពាល់ទៅលើគ្រប់វិស័យ។ ប៉ុន្តែក្នុងអំឡុងឆ្នាំ២០១៩ បានលេចឡើងនៅជំងឺដែលកាចសាហាវបំផុត គឺជំងឺវីរុសកូរ៉ូណា(កូវីត១៩) ជំងឺនេះ មានវត្តមានដំបូងនៅទីក្រុងអ៊ូហាននៃសាធារណៈរដ្ឋប្រជាមានិតចិន ដែលជាប្រភេទជំងឺឆ្លងបណ្តាលមកពីវីរុស SR ARS-COV-2 ដែលនាំឱ្យមនុស្សបានធ្លាក់ខ្លួនឈឺ ហើយមានរោកសញ្ញាពីស្ថានភាពស្រាលទៅជាធ្ងន់។ កាន់តែកម្រ និងជារឿងដែលគួរឱ្យបារម្ភបំផុតនោះ គឺជំងឺនេះអាចបណ្តាលឱ្យមនុស្សស្លាប់បាន។

ជាមួយ នឹងវឌ្ឍភាពល្អប្រសើរក្នុងការគ្រប់គ្រងការរីករាលដាលដល់អាយុជីវិតរបស់ប្រជាពលរដ្ឋរាជរដ្ឋាភិបាលបានអនុវត្តន៍យុទ្ធសាស្ត្រយ៉ាងតឹងរឹងបំផុត ស្របពេលនេះផងដែរ ជាមួយនិងវឌ្ឍភាពល្អប្រសើរក្នុងការផលិត និងការផ្គត់ផ្គង់វ៉ាក់សាំងកូវីត១៩ នៅក្នុងប្រទេសកម្ពុជាបានកំពុងចាត់ទុកវ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះសម្រាប់ពង្រឹងនិងស្តារប្រទេសជាតិទាំងមូលឡើងវិញ ដែលឈរលើគោលការណ៍ជាក់ស្តែងនិយម និងទន់ភ្លន់។ ក្រៅពីនេះថែមទាំងមានការបត់បែនទាន់ពេល និងយុទ្ធសាស្ត្រជាច្រើនទៀតទៅតាមសភាពការតម្រូវឱ្យសិស្សានុសិស្សគ្រប់រូបទទួលបានការសិក្សាដើម្បីបង្កើននូវគុណភាពវិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ នឹងតម្លាភាព។

ដោយផ្អែកលើការសិក្សាពីចម្ងាយពោល គឺតាមប្រព័ន្ធអេឡិចត្រូនិច នឹងបច្ចេកវិទ្យាទំនើបៗនាសម័យឌីជីថលដែលចាប់ផ្តើមអនុវត្តលើមាតិកាថ្មីរបស់សិស្ស ក្នុងអំឡុងពេលសិក្សាពីចម្ងាយដែលធានានូវប្រសិទ្ធភាពរបស់សិស្សានុសិស្ស ហើយក៏ក្រើនរំលឹកថាយើងចូលរួម និងទទួលបាននូវភាពជោគជ័យដែលទទួលបានពីការសិក្សាពីចម្ងាយនាំទៅរកភាពរីកចម្រើនក្នុងរយៈពេលដ៏ខ្លីនេះ។ អ្វីដែលសំខាន់ជាងនេះទៅទៀត គឺការអប់រំមានផលវិជ្ជមានធ្វើឱ្យមានការរំពឹងទុកការងារសម្រាប់មនុស្សគ្រប់រូប។ បុគ្គលដែលមានការអប់រំខ្ពស់នឹងទទួលបានអាជីពការងារមួយដ៏សមរម្យ។ ដូច្នេះហើយ ការអប់រំធ្វើឱ្យសិស្សចេះអាន និងសរសេរបានយ៉ាងស្ទាត់ជំនាញ។ បុគ្គលម្នាក់ៗក៏អាចកែលម្អការទំនាក់ទំនងផ្សេងទៀតតាមរយៈការអប់រំផងដែរ ជួយបង្កើនសមត្ថភាពរបស់មនុស្សក្នុងការប្រើប្រាស់បច្ចេកវិទ្យាបានយ៉ាងល្អ។ វាផ្តល់នូវសមត្ថភាពបច្ចេកទេសដែលត្រូវការដើម្បីប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព។ ក្រៅពីនេះថែមទាំងមានការបត់បែនទាន់ពេលវេលា នឹងយុទ្ធសាស្ត្រជាច្រើនទៀតទៅតាមសភាពការ តម្រូវឱ្យសិស្សានុសិស្សគ្រប់រូបទទួលបានការសិក្សាទោះបីប្រទេសជាតិជួបបញ្ហានូវការរីករាលនៃជំងឺក៏ដោយ គឺតម្រូវឱ្យសិស្សរៀនពីចម្ងាយតាមប្រព័ន្ធអ៊ីនធើណិត តាម E-Filling, Google Meeting, Zoom និងតាមប្រព័ន្ធសិក្សាថ្មីៗជាច្រើនបែបទៀត។ ក៏ដូចជាប្រធានបទមួយលើកឡើងថា"សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា"។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ពិភពលោកបានជួបប្រទះនូវព្រឹត្តិការណ៍ដ៏អាក្រក់មួយ ដែលពុំធ្លាប់កើតមានពីមុនមក ទាំងចំពោះសុខភាពសាធារណៈ និងសង្គមសេដ្ឋកិច្ចពោល គឺប៉ះពាល់ដល់សិស្សានុសិស្សគ្រប់រូបដែលមិនបានចូលរៀន

ដោយសារតែវិបត្តិជំងឺកូវីត១៩។ នៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ២០២០សេដ្ឋកិច្ចជាតិសម្រេចបានកំណើនអវិជ្ជមានដែលពុំធ្លាប់មានពីមុនមករួមមានវិស័យទេសចរណ៍ និងវិស័យអប់រំ។ ជាការពិតណាស់ វិស័យអប់រំនៅកម្ពុជាអាច នឹងមានកំណើនអវិជ្ជមានជ្រៅជាងនេះក្នុងករណីពុំមានការដាក់ចេញជាបន្តបន្ទាប់កន្លងមកនូវវិធានការណ៍អន្តរាគមន៍ទាន់ពេល និងប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលដែលសំដៅជានាលំនឹងជីវភាពប្រជាពលរដ្ឋ និងម្ខាងទៀតសំដៅរក្សាលំនឹងទៅលើវិស័យអប់រំ ដែលទទួលផលប៉ះពាល់យ៉ាងខ្លាំង។ ហេតុដូចនេះហើយ បានជាយើងត្រូវសិក្សាឱ្យបានច្បាស់ថា៖

១.តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការសិក្សាពីចម្ងាយ?

២.តើការសិក្សាពីចម្ងាយផ្តល់សារៈសំខាន់អ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទស្តីពី "សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា (The Importantce of Higher Education Distance Learning)" គឺក្នុងគោលបំណងចង់បង្ហាញអំពី៖

- ស្ថានភាពទូទៅនៃការសិក្សាពីចម្ងាយ
- វិធានការនៃការសិក្សាពីចម្ងាយទៅលើវិស័យអប់រំ
- ធ្វើឲ្យវិស័យអប់រំកាន់តែមានភាពងាយស្រួលក្នុងការសិក្សា
- ទទួលបានចំណេះដឹងថ្មីៗពីការសិក្សាពីចម្ងាយ
- សារៈសំខាន់នៃការសិក្សារពីចម្ងាយ
- គុណសម្បត្តិនិងគុណវិបត្តិ នៃការសិក្សាពីចម្ងាយ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សាស្រាវជ្រាវ ប្រធានបទនេះផ្តោតសំខាន់តែលើការសិក្សាពីចម្ងាយនៃកម្រិតឧត្តមសិក្សា និងគុណសម្បត្តិ នៃការសិក្សាដែលបានស្រាវជ្រាវពីក្រសួងអប់រំយុវជន និងកីឡាត្រឹមកម្រិតឧត្តមសិក្សាតែប៉ុណ្ណោះ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទនេះ គឺបានធ្វើការសិក្សាស្រាវជ្រាវក្នុងអំឡុងឆ្នាំ ២០២៣ ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូង ជាប្រភេទទិន្នន័យថ្មីដែលបានមកពីការប្រមូលដោយផ្ទាល់តាមយៈការប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យណាមួយដើម្បីយកមកដោះស្រាយបញ្ហាប្រឈម នឹងប្រធាបទ។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ ជាប្រភេទទិន្នន័យដែលមានស្រាប់ ហើយត្រូវបានយើងយកមកប្រើប្រាស់បន្តដើម្បីជាទិន្នន័យបន្ថែមក្នុងការសិក្សាស្រាវជ្រាវ។ ជាក់ស្តែងក្នុងប្រធានបទនេះ បានធ្វើការសិក្សាស្រាវជ្រាវបន្ថែមលើទិន្នន័យដែលមានស្រាប់ដូចជា សៀវភៅ របាយការណ៍ នឹងឯកសារនានាដែលបានមកពីបណ្ណាល័យ

ព្រមទាំងគេហទំព័រទាំងឡាយណាដែលមានប្រភពឈ្មោះគ្រឹះស្ថានអប់រំ។ ដើម្បីប្រាកដថារាល់អ្វីដែលបានលើកឡើងពិតជាមានអំណះអំណាងច្បាស់លាស់។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវដែលមានភាពត្រឹមត្រូវអាចទទួលយកបាន គឺយើងត្រូវប្រមូលទិន្នន័យឱ្យបានច្រើន ព្រោះការប្រមូលទិន្នន័យជាផ្នែកមួយយ៉ាងសំខាន់ នៅក្នុងកាស្រាវជ្រាវដែលឆ្លើយតបទៅ នឹងប្រធានបទនៃការស្រាវជ្រាវដែលបានកំណត់។ នៅក្នុងការស្រាវជ្រាវនេះដែរ យើងធ្វើការប្រមូលទិន្នន័យមានពីរប្រភព គឺការប្រមូលទិន្នន័យតាមការសម្ភាសន៍ដោយផ្ទាល់ នឹងការប្រមូលទិន្នន័យតាម(Internet Google…)។ ទោះបីការប្រមូលទិន្នន័យនេះទទួលបានព័ត៌មានច្រើនយ៉ាងណាក៏ដោយក៏មិនអាចយកទិន្នន័យទាំងស្រុងនោះមកបញ្ចូលបានទាំងស្រុងដែរត្រូវតែជ្រើសរើសយកទិន្នន័យណាដែលពាក់ព័ន្ធនិងប្រធានបទមុន នឹងទទួលបានទិន្នន័យនោះពិតណាស់ត្រូវតែមានការវិភាគ សំយោគ ដើម្បីឱ្យទិន្នន័យទាំងអស់នោះស៊ីគ្នាទៅនឹងគោលបំណងនៃប្រធានបទដែលជាកត្តាសំខាន់ ក្នុងការជួយគាំទ្រខ្លឹមសារនៃប្រធានបទកុំឱ្យមានការប្រាស់ចាកអត្ថន័យ ខ្លឹមសាររបស់ប្រធានទាំងមូល ហេតុដូចនេះហើយការសិក្សាស្រាវជ្រាវមានសារៈសំខាន់ដូចខាងក្រោម៖

- យល់ដឹងកាន់តែច្បាស់លើវិស័យអប់រំទោះបីប្រទេសជួប នឹងជំងឺរាតត្បាតកូវីដ-១៩ក៏ដោយ
- ស្គាល់ច្បាស់នៃកម្មវិធីផ្សេងៗដែលពាក់ព័ន្ធលើការសិក្សាតាមប្រព័ន្ធឌីជីថល
- ធ្វើឱ្យសិស្សានុសិស្សងាយស្រួលសិក្សា ងាយស្រួលយល់
- ចេះប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ
- មានភាពប៉ិនប្រសព្វក្នុងការប្រើប្រាស់កម្មវិធី រដ្ឋបាល Microsoft Office
- យល់ដឹងកាន់តែច្បាស់ពីរបៀបចងក្រងឯកសារស្រាវជ្រាវ
- មានភាពរហ័សក្នុងការគិត ភាពក្លាហាន
- មានភាពអត់ធ្មត់ នឹងមានភាពតស៊ូគ្រប់ស្ថានភាព
- បង្កើននូវចំណេះដឹងក្រោយពីធ្វើការស្រាវជ្រាវ
- ជំរុញដល់ការស្រាវជ្រាវឱ្យមានភាពរីកចម្រើន
- ជំរុញឱ្យប្រទេសជាតិមានការអភិវឌ្ឍន៍។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

### ជំពូកទី១៖ សេចក្តីផ្តើម

បានបង្ហាញ អំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់ នឹងវិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្រ្តនៃការស្រាវជ្រាវ។

### ជំពូកទី២៖ រំលឹកទ្រឹស្តី

បង្ហាញអំពី ការលើកយករំលឹកទ្រឹស្តី បទពិសោធន៍ ឬការអនុត្តន៍ជាមូលដ្ឋាន វិស័យអប់រំ នឹងផលវិជ្ជមាន នឹងផលអវិជ្ជមាន។

### ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ

បង្ហាញអំពី ស្ថានភាពទូទៅពីការសិក្សាពីចម្ងាយ ដូចជាប្រវត្តិនៃការសិក្សាពីចម្ងាយ ។

### ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

បង្ហាញអំពី ភាពខ្លាំង និងភាពខ្សោយនៃការសិក្សាពីចម្ងាយ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

បង្ហាញអំពី ការសន្និដ្ឋាន និងសរុបសេចក្តី រួមមកក្រោយពីបានធ្វើការស្រាវជ្រាវពីស្ថានភាពនៃការសិក្សាពីចម្ងាយរួចមក និងការផ្តល់អនុសាសន៍ ដើម្បីកែតម្រូវនូវចំណុចខ្វះខាត។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# សារៈសំខាន់នៃការសិក្សាពីចម្ងាយ

## ២.១ លក្ខណៈទូទៅនៃសារៈសំខាន់អំពីការសិក្សាពីចម្ងាយ

### ២.១.១ និយមន័យ

ការសិក្សា គឺការរៀន ការទន្ទេញ ការរៀនសូត្រ ការប្រុងប្រយ័ត្នរក្សាមារយាទ អាប្បកិរិយាឱ្យបានល្អ[1]។

ការសិក្សា គឺជាសមត្ថភាពមូលដ្ឋានដ៏សំខាន់បំផុតមួយនៃជីវិតរស់នៅរបស់មនុស្ស[2]។

ការសិក្សា គឺសំដៅទៅដល់ដំណើរការដែលសង្គមបានបណ្តុះបណ្តាលចំណេះដឹង គុណតម្លៃ និងទក្ខភាព (ជំនាញ) យ៉ាងល្អិតល្អន់ដែលមរតកវប្បធម៌របស់សង្គមនោះ សន្សំមកពីជំនាន់មួយទៅជំនាន់មួយតាមរយៈសាលារៀន មហាវិទ្យាល័យ និងវិទ្យាស្ថានដទៃទៀត[3]។

### ២.១.២ ប្រវត្តិនៃការសិក្សាពីចម្ងាយ

ប្រពៃណីការសិក្សានៅប្រទេសកម្ពុជាត្រូវបានចេញពីវត្តអារាមហើយព្រះសង្ឃ គឺជាគ្រូបង្រៀន។ សិស្សភាគច្រើន គឺសុទ្ធតែក្មេងប្រុសហើយការសិក្សា គឺត្រូវបានកំណត់ឱ្យទន្ទេញដដែលៗ ដូចព្រះសង្ឃទន្ទេញបាលី។ អំឡុងពេលបារាំងគ្រប់គ្រង ប្រព័ន្ធអប់រំជាផ្នែកលើភាសាបារាំងត្រូវបាន ផ្តើមបញ្ជ្រាបចូលជាលំដាប់។ ដំបូងបារាំងបានធ្វេសប្រហែសចំពោះការអប់រំនៅប្រទេសកម្ពុជា វិទ្យាល័យមួយចំនួនដែលសិស្សបានបញ្ចប់ការសិក្សានៅឆ្នាំ១៩៣១ ហើយសិស្សត្រឹមតែ៥០០០ទៅ ៦០០០០នាក់ប៉ុណ្ណោះ ដែលត្រូវបានចុះឈ្មោះចូលរៀនក្នុងសាលាបឋមសិក្សាក្នុងឆ្នាំ១៩៣៦។ ក្នុងឆ្នាំដែលទទួលបានឯករាជ្យភ្លាមៗ ចំនួនសិស្សបានកើតឡើងយ៉ាងគួរឱ្យកត់សំគាល់។ ចាប់ពីសតវត្សន៍ទី២០រហូតដល់ឆ្នាំ១៩៧៥ ប្រព័ន្ធនៃការអប់រំបានប្រតិបត្តិទៅតាមគំរូរបស់បារាំង។ ប្រព័ន្ធនៃការអប់រំត្រូវបានបែងចែកទៅជា បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យហើយនឹងកម្រិតខ្ពស់។ ការអប់រំក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានស្ថិតនៅ ក្រោមអំណាចច្បាប់ក្រសួងអប់រំដែលជាអ្នកមើលការខុសត្រូវទាំងស្រុង។ គណៈកម្មាធិការវប្បធម៌នៅក្រោមក្រសួងអប់រំ គឺទទួលខុសត្រូវចំពោះការបង្កើតឡើងនៅភាសាកម្ពុជា។

ការអប់រំជាដំបូងបានចែកជាពីរជុំនៃបីឆ្នាំដូចគ្នា គឺត្រូវបានបញ្ចូលខាងក្រៅប្រព័ន្ធអប់រំ នឹងក្នុងប្រព័ន្ធអប់រំ។ ការសម្រេចជោគជ័យនៃការប្រឡងបញ្ចប់បានទទួលវិញ្ញាបនបត្របន្ទាប់ពីវគ្គនីមួយៗ។ វគ្គសិក្សាអប់រំដំបូងស្ថិតលើប្រវត្តិសាស្ត្រ សីលធម៌ ពលរដ្ឋ ការព្រាង ភូមិសាស្ត្រ ភាសាហើយ និងវិទ្យាសាស្ត្រ។ ថែមទាំងបានបញ្ចូលមុខវិជ្ជាអប់រំផ្លូវចិត្តហើយ នឹងការងារហត្ថកម្ម។ ការសិក្សាភាសាបារាំងបានចាប់ផ្តើមក្នុងរយៈពេលពីរឆ្នាំ។ នៅក្នុងឆ្នាំ១៩៨០ សាលាបឋមសិក្សាបានដំណើរការចាប់ពីថ្នាក់ទី១ទៅដល់ថ្នាក់ទី៤ ដោយមានការសន្មត់តាមទ្រឹស្តីសាលាបឋមសិក្សាមួយបានបម្រើការតាមភូមិនីមួយៗ នឹងការអប់រំអនុវិទ្យាល័យក៏ត្រូវបានបែងចែកជាពីរជុំ។ ចាប់ផ្តើមនៅឆ្នាំ១៩៦៧ បីឆ្នាំក្រោយមកសាលាអនុវិទ្យាល័យ គឺបានចែកទៅជាបីផ្នែក យោងតាមមុខវិជ្ជាគោលគណិតវិទ្យា នឹងវិទ្យាសាស្ត្រ កសិកម្ម នឹងជីវវិទ្យា។ នៅចុងឆ្នាំ១៩៦០ នឹងដើមឆ្នាំ១៩៧០ ប្រទេសបានប្រកាសការអប់រំបច្ចេកវិទ្យានៅក្នុងរបបសាធារណរដ្ឋកម្ពុជា មធ្យមសិក្សាបឋមភូមិបានប្តូរទៅជាប្រាំមួយឆ្នាំ។

1 https://videoslearning.com/1-1152/
2 https://mengkorngdata.files.wordpress.com/2016/01/...
3 https://km.wikipedia.org/wiki/%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%A2%E1%9E%94%E1%9F%8B%E1%9E%9A%E1%9F%86

ក្នុងអំឡុងពេលរបបខ្មែរក្រហម ការអប់រំ គឺធ្លាក់ចុះ និងត្រូវបានលុបបំបាត់ប្រព័ន្ធអប់រំចោល។ សាលារៀនត្រូវបានបិទ និងបានអប់រំប្រជាជន នឹងគ្រូបង្រៀនធ្វើជាកូនចៅរបស់គេ គ្រប់គ្រង់ដោយគ្រោធគ្រោតនិងអាក្រក់បំផុត ប្រហារជីវិត។ នៅពេលចាប់ផ្តើមនៃសតវត្សន៍ឆ្នាំ១៩៧០ គ្រូបង្រៀនជាង ២ម៉ឺននាក់បានរស់នៅក្នុងប្រទេសកម្ពុជា គ្រូបង្រៀនប្រមាណជាង៥ពាន់នាក់ត្រូវបានសម្លាប់ក្រោមរបបខ្មែរក្រហម។

មុនបារាំងរៀបចំប្រព័ន្ធការអប់រំតាមរបៀបប្រទេសភាគខាងលិច វត្តអារាមជាកន្លែងសិក្សារបស់ព្រះសង្ឃ ហើយព្រះសង្ឃ គឺជាគ្រូបង្រៀនត្រូវបានយកមកជាកម្មវិធីសិក្សានៅប្រទេសកម្ពុជា។ ព្រះសង្ឃមានតួនាទីសំខាន់សម្រាប់ការអប់រំដល់ការសិក្សា ការបង្រៀនតាមរបៀបនៃព្រះពុទ្ធសាសនា នឹងប្រវត្តិសាស្ត្រនិងសារៈសំខាន់នៃគុណធម៌។ តួនាទីផ្សេងទៀតព្រះសង្ឃ គឺជាមាតាបិតាទីពីររបស់ពួកគេ នៅតាមវត្តអារាមក្មេងប្រុសស្រី គឺមិនត្រូវបានអនុញ្ញាតឱ្យទៅសិក្សានៅគ្រឹះស្ថាន សិក្សាដោយបានបង្រៀនឱ្យចេះអាន និងចេះសរសេរឡើយ ហើយពួកគេត្រូវបានបង្រៀននៅថ្នាក់ដំបូងនៃព្រះពុទ្ធសាសនា។ ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស នឹងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ នឹងមិនផ្លូវការ ជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការធានាឱ្យការសិក្សាមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន នឹងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ការប្រែប្រួលសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម នឹងបច្ចេកវិទ្យា គមនាគមន៍ នឹងព័ត៌មានតម្រូវឱ្យមានការធ្វើបច្ចុប្បន្នកម្ម នឹងកែលម្អកម្មវិធីអក្ខរកម្មដែលសង្កត់ធ្ងន់ទៅលើការចេះអក្សរ នឹងលេខទៅជាកម្មវិធីសិក្សាពេញមួយជីវិតដែលសង្កត់ធ្ងន់លើបំណិនបច្ចេកទេសវិជ្ជាជីវៈ បំណិនអាជីព នឹងបំណិនអរូបវន្តដែលអ្នកសិក្សាអាចសិក្សានៅគ្រប់ពេលវេលា គ្រប់ទីកន្លែង នឹងគ្រប់មធ្យោបាយ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានសម្រាប់គាំទ្រសកម្មភាពសិក្សា[4]។

**២.១.៣ ទ្រឹស្តីនៃការសិក្សាពីចម្ងាយ**

ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស នឹងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ នឹងមិនផ្លូវការ ជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការធានាឱ្យការសិក្សាមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន នឹងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា។ ការប្រែប្រួលសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម នឹងបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានតម្រូវឱ្យមានការធ្វើបច្ចុប្បន្នកម្ម នឹងកែលម្អកម្មវិធីអក្ខរកម្មដែលសង្កត់ធ្ងន់ទៅលើការចេះអក្សរ នឹងលេខទៅជាកម្មវិធីសិក្សាពេញមួយជីវិតដែលសង្កត់ធ្ងន់លើបំណិនបច្ចេកទេសវិជ្ជាជីវៈ បំណិនអាជីព នឹងបំណិនអរូបវន្ត ដែលអ្នកសិក្សាអាចសិក្សានៅគ្រប់ពេលវេលា គ្រប់ទីកន្លែង នឹងគ្រប់មធ្យោបាយ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ នឹងព័ត៌មានសម្រាប់គាំទ្រសកម្មភាពសិក្សា។

[4] ttps://km.wikipedia.org/wiki/វិស័យអប់រំនៅកម្ពុជា#ប្រវត្តិ

## ២.២ មូលហេតុដែលបណ្តាលឱ្យមានការសិក្សាពីចម្ងាយ

### ២.២.១ និយមន័យ

ការសិក្សាពីចម្ងាយ គឺជាជម្រើសមួយសម្រាប់ការរៀនតាមថ្នាក់ប្រពៃណី ដែលអនុញ្ញាតឱ្យបុគ្គលបន្តការសិក្សារបស់ពួកគេ នឹងបញ្ចប់វគ្គសិក្សាពីចម្ងាយគ្រប់ពេលវេលា នឹងគ្រប់ទីកន្លែងដោយមិនចាំបាច់មានវត្តមាននៅក្នុងថ្នាក់រៀន ឬនៅក្នុងបរិវេណសាលាណាមួយឡើយ។[5]

ការសិក្សាពីចម្ងាយ គឺជាវិធីសាស្ត្រមួយដែលសិស្សអាចទទួលបានការអប់រំសម្រាប់ ការអភិវឌ្ឍន៍សម្បទាទាំងបួន ពុទ្ធិសម្បទា បំណិនសម្បទា កាយសម្បទា នឹងចរិយាសម្បទាដោយពុំចាំបាច់មានវត្តមាននៅសាលារៀន ឬជួបជាមួយគ្រូដោយផ្ទាល់[6]។

### ២.២.២ ប្រព័ន្ធអប់រំនៃការសិក្សា

ការអភិវឌ្ឍនៃប្រព័ន្ធអប់រំបានចាប់ផ្តើមកំពុងធ្វើការបង្ហាញសារជាថ្មីតាមរយៈគ្រឹះស្ថានសិក្សារបស់របបសាធារណៈរដ្ឋកម្ពុជា។ ក្នុងឆ្នាំ១៩៨៦ តាមរយៈគ្រឹះស្ថានសិក្សា សំខាន់ៗនៃគ្រឹះស្ថានឧត្តមសិក្សាត្រូវបានរាយការណ៍ក្នុងរបបសាធារណៈរដ្ឋកម្ពុជាថា៖ មហាវិទ្យាល័យវេជ្ជវិជ្ជា នឹងគិលានុប្បដ្ឋាន(បានបើកឡើងវិញនៅឆ្នាំ១៩៨០ សិក្សារយៈពេល៦ឆ្នាំ) មហាវិទ្យាល័យកសិកម្មចំការដូង(បានបើកក្នុងឆ្នាំ១៩៨៥) វិទ្យាស្ថានបច្ចេកទេសកម្ពុជា USSR(ដែលរួមបញ្ចូលកម្មវិធីបច្ចេកទេស នឹងវិស្វកម្មសំណង់ស៊ីវិល) វិទ្យាស្ថានអក្សរសាស្ត្រ (ដែលបង្រៀនដោយសាស្ត្រាចារ្យជនជាតិ វៀតណាម អាល្លឺម៉ង់ រ៉ុស្ស៊ី និង អេស្ប៉ាញ)។ វិទ្យាស្ថានពាណិជ្ជកម្ម មជ្ឈមណ្ឌលអប់រំ Pedagogical (មុនឆ្នាំ១៩៧៩) សាលាគរុវិជ្ជាជាន់ខ្ពស់ នឹងសាលាវិចិត្រសិល្បៈ។ ការសរសេរអំពីប្រព័ន្ធអប់រំក្រោមរបបសាធារណៈប្រជាមានិតកម្ពុជា រិហ្គីរីបញ្ចេញទាំងរាជរដ្ឋាភិបាល នឹងប្រជាជនត្រូវបានធ្វើនិទស្សន៍ដើម្បីអបអរសាទរសំរាប់ការអប់រំ គឺជាចំណងជើងផ្សេងគ្នាមុនឆ្នាំសង្គ្រាម។ សុខចិត្តលះបង់ពេលវាលាជាច្រើនដើម្បីភាសាខ្មែរ នឹងអក្សរសាស្ត្រមុនសង្គ្រាម នឹងរហូតដល់ឆ្នាំ១៩៨៤-១៩៨៥ ក្នុងនោះក៏មានការបង្រៀនភាសាបរទេសដែរ។ គាត់បានកត់សំគាល់ថា គម្រោងសាលាមធ្យមសិក្សាមានបួនម៉ោងក្នុងមួយសប្តាហ៍សម្រាប់សិក្សាភាសាបរទេសឱ្យស្របតាមប្រទេសរ៉ុស្ស៊ី អាល្លឺម៉ង់ ឬក៏ប្រទេសវៀតណាម ប៉ុន្តែមិនមានគ្រូបង្រៀនគ្រប់គ្រាន់ឡើយ[7]។

### ២.២.៣ ទ្រឹស្តីនៃយុទ្ធសាស្ត្រការសិក្សា

បើទោះបីជាមានការខិតខំរៀនសូត្រយ៉ាងណាក៏ដោយ សិស្ស-និស្សិតមួយចំនួននោះក៏មិនអាចរាប់បញ្ចូលទៅក្នុងចំណោមសិស្សពូកែបានដែល។ ត្រូវចងចាំថា គួរធ្វើខ្លួនឱ្យក្លាយជាមនុស្ស"ពូកែ" មិនមែន"ពូកែរៀន" នោះទេ ខាងក្រោមនេះ គឺជាយុទ្ធសាស្ត្រក្នុងការសិក្សាមួយចំនួន៖

**ទីកន្លែងសម្រាប់រៀន៖** មានមនុស្សមួយចំនួនគិតថាកន្លែងសម្រាប់សិក្សា គឺមិនសូវជាសំខាន់ នឹងចាំបាច់នោះទេ។ ពួកគេគិតថាគ្រាន់តែផ្តោតអារម្មណ៍ទៅលើការមើលមេរៀននោះ គឺវាគ្រប់គ្រាន់ណាស់ទៅហើយ។ ពួកគេកំពុងតែគិតខុសហើយទីកន្លែង គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកផ្ចង់អារម្មណ៍សិក្សាបានល្អ។ ទីកន្លែងស្ងប់ស្ងាត់ផារសុខភាព គឺជាអ្វីដែលនិស្សិតត្រូវការ ។ ទីកន្លែងទាំងនោះមានដូចជាបណ្ណាល័យ ហាងកាហ្វេ ឬក៏អាចជាផ្ទះ។

---

[5] https://ahaslides.com/km/blog/distance-learning/

[6] https://npn.news/post/55962/2928

[7] វិស័យអប់រំនៅកម្ពុជា - វិគីភីឌា ( wikipedia.org )

**យកអ្វីដែលគួរតែយក៖** សម្ភារៈសិក្សាមួយចំនួនដែលអ្នកត្រូវការចាំបាច់សម្រាប់មើលមេរៀន ឬធ្វើលំហាត់ មិនគួរត្រូវបានភ្លេចភ្ជាប់ទៅជាមួយនោះទេ។ ព្រោះវាជាការខ្ជះខ្ជាយពេលវេលាច្រើនណាស់កាលដែលអ្នកត្រឡប់ទៅយកសម្ភារៈសិក្សាដែលអ្នកភ្លេចនោះមក សម្ភារៈទាំងនោះអាចជាសំណុំឯកសារនានាៗដែលលោកគ្រូប្រគល់ឱ្យ។

**ការសម្រួលពាក្យ៖** ការសិក្សាមិនមែនត្រូវការត្រឹមតែសមត្ថភាពក្នុងការទន្ទេញ ឬចាំតាមនោះទេ តែយើងគួរតែយល់នូវអ្វីដែលយើងកំពុងតែទន្ទេញ នឹងសម្រួលវាឱ្យទៅជាពាក្យរបស់អ្នក។ ការសម្រួលពាក្យនេះវាពិតជាមានប្រសិទ្ធភាពខ្ពស់ដែលធ្វើឱ្យអ្នកចងចាំបានយូរ។

**ការអនុវត្តន៍ជាក្រុម៖** ពាក្យអង់គ្លេសមួយឃ្លាពោលថា "Practice Makes Perfect"។ ជាការពិតណាស់ យើងគួរតែធ្វើតេស្តសាកល្បងសម្ថភាពរបស់ខ្លួនដើម្បីដឹងថាអ្នកចេះបានដល់កម្រិតណា។ នេះ គឺជាវិធីសាស្ត្រតែមួយគត់ដែលអ្នកពង្រឹងចំណុចខ្វះខាតរបស់អ្នកឱ្យមានភាពល្អប្រសើរឡើងវិញ។ ពេលខ្លះអ្នកក៏អាចធ្វើតេស្តសាកល្បងសម្ថភាពនោះជាក្រុមទោះបីជាមានសមាសធាតុមកពីថ្នាក់ផ្សេងគ្នាក្តី។ ពីព្រោះពួកគេអាចជួយពន្យល់ចំណុចដែលអ្នកខ្វះខាត ឬផ្លាស់ប្តូរឯកសារសិក្សាគ្នាទៅវិញទៅមកដែលនេះ គឺជាការប្រសើរសម្រាប់អ្នក។

**ធ្វើតារាងកាលវិភាគសិក្សាសម្រាប់ខ្លួនអ្នក៖** មានមនុស្សជាច្រើនចំណាយពេលសិក្សាតែពេលណាដែលពួកគេចង់តែប៉ុណ្ណោះ។ ធ្វើដូច្នេះអាចធ្វើឱ្យអ្នកបង្កើតទម្លាប់អាក្រក់ខ្ជិលដែលបណ្តាលមកពីពាក្យដោះសារថា "ជាប់រវល់" របស់អ្នក។ អ្នកគួរតែមានពេលវេលាមួយសមរម្យសម្រាប់ស្វ័យសិក្សាបើទោះបីជាវាមានរយៈពេលខ្លីយ៉ាងណាក៏ដោយ វាអាចជួយឱ្យអ្នកត្រៀមខ្លួនរួចជាស្រេចសម្រាប់ថ្ងៃប្រឡង[8]។

## ២.៣ សារៈសំខាន់នៃការសិក្សាពីចម្ងាយ

### ២.៣.១ និយមន័យសារៈសំខាន់

សារៈសំខាន់ គឺជាចរិតលក្ខណៈនៃអ្វីៗដែលធំ ដែលមានប្រយោជន៍ដែលគួររិះគិតយ៉ាងហ្មត់ចត់[9]។

សារៈសំខាន់មានន័យថា ភាពសំខាន់ដែរគួរតែមាន[10]។

**សារៈ+សំខាន់**

**សារៈ៖** មានន័យថា ខ្លឹម, សេចក្តីខ្ជាប់ខ្ជួន, មាំមួន, រឹងប៉ឹង, កម្លាំង, អំណាច, ក្លាហាន, ផលប្រយោជន៍ អង់អាច,សេចក្តីពិត, តម្លៃ, ទ្រព្យ, សម្បត្តិ, របស់សុទ្ធ[11]។

**សំខាន់៖** មានន័យថា ប្រសើរ, ថ្លៃថ្នូរ, លើសលែង, ចំណាប់,ដែលគួរទុកជាគ្រឿងសម្គាល់, ដែលគួរយកជាបែប,ជាគំរូ[12]។

8 វិធីសាស្ត្រក្នុងការសិក្សាឲ្យមានប្រសិទ្ធភាព | ខ្មែរអ្នកអប់រំ (khmereducator.org)
9 https://videoslearning.com/1-1002/
10 https://www.sangapac.com/dictionary/sa/5997
11 https://thmeythmey.com/?page=detail&id=64754
12 https://videoslearning.com/1-2367/

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣

# សារៈសំខាន់នៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា

## ៣.១ ស្ថានភាពទូទៅនៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា

ការអប់រំកម្រិតឧត្តមសិក្សា ជាទូទៅសំដៅលើការអប់រំលើសពីកម្រិតមធ្យមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាអាចបែងចែកជាពីរប្រភេទគឺៈ រាជបណ្ឌិត្យសភាសាកលវិទ្យាល័យ នឹងមហាវិទ្យាល័យ។ ការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជា រួមមានសញ្ញាបត្របរិញ្ញាបត្ររង បរិញ្ញាបត្រ ៤ឆ្នាំ ថ្នាក់អនុបណ្ឌិត ២ឆ្នាំ នឹងបណ្ឌិត៣ឆ្នាំដល់៦ឆ្នាំ។ មុនពេលមានការអភិវឌ្ឍន៍ដូចនាពេលបច្ចុប្បន្ននេះ ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាត្រូវបានកម្ទេចចោលក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) ហើយទើបតែអាចកសាងឡើងវិញបានបន្ទាប់ពីសម័យកាលបានបញ្ចប់។ សម័យនេះ ឃើញមានការបើកឡើងវិញនូវសាកលវិទ្យាល័យមួយចំនួនដែលបានសាងសង់មុនសម័យខ្មែរក្រហមដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញជាដើម។ ចាប់តាំងពីពេលនោះមកព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមពង្រីកនិងរៀបចំរចនាសម្ព័ន្ធថ្នាក់ឧត្តមសិក្សាឡើងវិញ ដោយបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជន នឹងណែនាំកម្មវិធីបង់ថ្លៃសម្រាប់គ្រឹះស្ថានសាធារណៈ និងឯកជន។ នៅឆ្នាំ១៩៩៧ គ្រឹះស្ថានឧត្តមសិក្សាឯកជនដំបូងគេត្រូវបានបង្កើតឡើងក្រោមគោលនយោបាយនេះ។ ក្រោយមកឧត្តមសិក្សាទាំងសាធារណៈ នឹងឯកជនបានចាប់ផ្តើមកើនឡើងពី៨គ្រឹះស្ថាន ក្នុងឆ្នាំ១៩៩៧ ដល់ ៧០គ្រឹះស្ថាន ក្នុងឆ្នាំ២០០៩ ដល់ ១២៨ គ្រឹះស្ថានក្នុងឆ្នាំ២០២០ ដែលមាននៅក្នុងខេត្ត នឹងរាជធានីចំនួន ២០គ្រឹះស្ថាន។ ជាងនេះទៅទៀតក្រសួងអប់រំ យុវជន និងកីឡា ត្រួតពិនិត្យគ្រឹះស្ថានឧត្តមសិក្សាចំនួន ៨០គ្រឹះស្ថានក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង១២៨គ្រឹះ ស្ថាន។ ការសិក្សាពីចម្ងាយចាប់ផ្តើមក្នុងអំឡុងពេលនៃការផ្អាកដំណើរការគ្រឹះស្ថានសិក្សា ដោយសារព្រឹត្តិការណ៍សហគមន៍ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ គ្រឹះស្ថានសិក្សាបានដំណើរការការបង្រៀន នឹងរៀនពីចម្ងាយតាមគ្រប់រូបភាព។ រាជរដ្ឋាភិបាលបានរៀបចំឡើងដើម្បីឱ្យសិស្សបានសិក្សាងាយស្រួល នឹងធានានូវសុវត្ថិភាពខាងសុខភាពរបស់សិស្សានុសិស្សគ្រប់រូប។ ទោះបីជា ប្រទេសបានជួបនឹងបញ្ហាជំងឺកូវីត១៩ ក៏ដោយ ក៏ការសិក្សានូវតែបន្តទៅមុខជាលំដាប់ដែលធ្វើឱ្យប្រព័ន្ធអប់រំនៅកម្ពុជា នៅតែរីកចម្រើនទៅមុខថែមទាំងមានភាពងាយស្រួលដល់សិស្សគ្រប់រូបក្នុងការរៀនសូត្រ។ លើសពីនេះទៅទៀត សិស្សគ្រប់រូបក៏ទទួលបានចំណេះដឹងថ្មីៗទាក់ទង នឹងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗដែលជាមធ្យោបាយថ្មីក្នុងការសិក្សា។

### ៣.១.១ ប្រវត្តិនៃការសិក្សាពីចម្ងាយកម្រិតឧត្តមសិក្សា

ថ្នាក់ឧត្តមសិក្សាត្រូវបានអន់ថយជាងបឋមសិក្សា នឹងមធ្យមសិក្សារហូតដល់ចុងសតវត្សន៍ឆ្នាំ ១៩៥០។ ភាពកើនឡើងវិញនៃថ្នាក់ឧត្តមសិក្សាមុនសត្សន៍ឆ្នាំ១៩៦០ គឺមានវិទ្យាស្ថានជាតិសិក្សា ច្បាប់នយោបាយ នឹងសេដ្ឋកិច្ចដែលបានហ្វឹកហ្វឺនបម្រើពលរដ្ឋ។ នៅចុងសតវត្សន៍ឆ្នាំ១៩៥០សាលាមានសិស្សានុសិស្សចំនួន ២៥០នាក់។ ប្រជាជនកម្ពុជា នឹងអ្នកដែលទទួលបានអាហារូបករណ៍ត្រូវបានរាជរដ្ឋាភិបាលឱ្យមានសិទ្ធិជ្រើសរើសកម្រិតថ្នាក់សិក្សានៅសាកលវិទ្យាល័យសហរដ្ឋអាមេរិក។ ក្រោយទទួលបានឯករាជ្យការកើនឡើងនៃចំនួនសិស្សដែលបានចុះឈ្មោះទៅរៀននៅសាកលវិទ្យាល័យសហរដ្ឋអាមេរិក កាណាដា ចិន ចក្រភពអង់គ្លេស

បារាំង សូវៀត នឹងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់មានការកើនឡើងជាលំដាប់។ ដោយឆ្នាំ១៩៧០ សាកលវិទ្យាល័យមានចំនួនសិស្សសរុបដែលបានចុះឈ្មោះជិត៩០០០ នាក់នៅកម្ពុជា។ សកលវិទ្យាល័យភ្នំពេញដែលជាសាកលវិទ្យាល័យធំជាងគេបង្អស់មានសិស្សប្រុសជិត ៤៥៧០នាក់ នឹងថែមសិស្សស្រីជាង ៧៣០នាក់ ក្នុងប្រាំបីផ្នែកមានមនុស្សសាស្ត្រ វិទ្យាសាស្ត្រ នឹងបច្ចេកវិទ្យា ច្បាប់ នឹងសេដ្ឋកិច្ច ថ្នាំកែរោគ គិលានុដ្ឋានពាណិជ្ជសាស្ត្រ គរុកោសល្យ នឹងឧត្តមគរុកោសល្យ។ សាកលវិទ្យាល័យដែលបានប្រតិបត្តិក្នុងខេត្តកំពង់ចាម តាកែវ បាត់ដំបង នឹងក្នុងរាជធានីភ្នំពេញ មានសាកលវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម នឹងសាកលវិទ្យាល័យវិចិត្រសិល្បៈ។

ក្នុងអំឡុងពេល នៃការរីករាលដាលនៃជំងឺកូវីដ១៩ ក្រសួងបានបន្តពន្យារពេលបើកដំណើរការសាលារៀនឡើងវិញក្រោយវិស្សមកាលតូចនៅទូទាំងប្រទេស។ ដើម្បីធានាថាអ្នករៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធអាចបន្តរៀនបាននៅតាមផ្ទះ ក្រោមការជួយសម្របសម្រួលពីមន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ អាជ្ញាធរដែនដី គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ នឹងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំការផលិតវីដេអូសម្រាប់ការបង្រៀនពីចម្ងាយ នឹងតាមប្រព័ន្ធអេឡិចត្រូនិច (E-Learning) ជាកម្មវិធីអក្ខរកម្ម នឹងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ដើម្បីពង្រីកការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ។ ដើម្បីឱ្យការសិក្សាពីចម្ងាយដែលស្របទៅ នឹងកម្មវិធីអក្ខរកម្ម នឹងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមានប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ត្រីអប់រំក្រៅប្រព័ន្ធនៅតាមឃុំ សង្កាត់ គ្រូបង្រៀនជាប់កិច្ចសន្យា និងដៃគូអភិវឌ្ឍ។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ កម្រិតឧត្តមសិក្សា

#### ក.ចក្ខុវិស័យ

ការអប់រំ គឺជាកូនសោរមួយដែលមានតម្លៃបំផុតសម្រាប់បើកទ្វារចូលទៅក្នុងពិភពលោកដ៏ទំនើប ដែលពោរពេញដោយសក្តានុពលនៃការអភិវឌ្ឍន៍ នឹងជាទ្រព្យធនដែលមនុស្សជាតិគ្រប់គ្នាត្រូវការដោយខានមិនបាន ក្នុងការធ្វើឱ្យសម្រេចបាននូវជីវភាពរស់នៅប្រកបដោយសុខដុមរមនាដោយមាន ឧត្តមភាព សន្តិភាព សេរីភាព នឹងយុត្តិធម៌សង្គម។ ជាការពិតណាស់ការសិក្សា គឺជាដំណើរការមួយដែលត្រូវធ្វើឡើងពេញមួយជីវិតរៀនហើយរៀនទៀត រៀនមិនចេះចប់ ហើយចំណេះដឹងដែលបានពីការសិក្សាទាំងនោះ គឺជាធនធានមនុស្សដ៏មានតម្លៃបំផុតសម្រាប់ធ្វើការអភិវឌ្ឍន៍ប្រទេសជាតិឱ្យបានរីកចម្រើន នឹងរត់ឱ្យទាន់ចលនាសកលភាវូបនីយកម្មនៅលើសកលលោកនាពេលបច្ចុប្បន្ននេះ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ នឹងប្រសិទ្ធភាពនៅកម្ពុជា គឺការសាងសមត្ថភាព នឹងការអភិវឌ្ឍន៍ធនធានមនុស្ស។

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព នឹងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនលើផ្នែកចំណេះដឹង នឹងចំណេះធ្វើជាមូលដ្ឋាន។ ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើក្រសួងអប់រំ យុវជន និងកីឡាមានបេសកកម្មដឹកនាំ គ្រប់គ្រង នឹងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា នឹងការរីកចម្រើននៅក្នុងតំបន់ នឹងសកលលោក ។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺការអភិវឌ្ឍន៍យុវជនកម្ពុជាលើគ្រប់វិស័យនិងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ នឹងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ នឹងប្រជាពលរដ្ឋរបស់ខ្លួន ។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថា យុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ នឹងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារពោល គឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ នឹងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេ នឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ នឹងលើសកលលោក នឹងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍន៍សង្គម នឹងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។ ការធ្វើសមាហរណកម្មទៅក្នុងសមាគមអាស៊ានឆ្នាំ២០១៥ នឹងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមក្នុងឆ្នាំ ២០៣០ ទាមទារឱ្យមានការវិនិយោគបន្ថែមទៀតក្នុងវិស័យអប់រំ។ ធនធានមនុស្សដែលមានវិជ្ជាជីវៈត្រឹមត្រូវ នឹងមានគុណភាពព្រមទាំងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក៏ត្រូវដាក់ចូលក្នុងវិស័យអប់រំផងដែរ (ប្រទេសក្នុងអាស៊ានដែលជោគជ័យក៏ទទួលបទពិសោធន៍ពីការបង្កើន ការវិនិយោគទៅក្នុងវិស័យអប់រំ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប)។

ក្រសួងទទួលស្គាល់ពីសារៈសំខាន់ក្នុងការជំរុញឱ្យវិស័យទាំងមូលអាចធ្វើការជាមួយគ្នាដើម្បីឆ្លើយតប នឹងតម្រូវការសង្គមនិងសេដ្ឋកិច្ច។ ចំណុចផ្ដោតរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ គឺប្រមូលផ្ដុំនូវសមិទ្ធផលដែលមានកន្លងមកការផ្ដល់ការអប់រំប្រកបដោយគុណភាព នឹងភាពពាក់ព័ន្ធដល់ការអភិវឌ្ឍប្រទេសជាតិ។ ការផ្ដល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ នឹងគណនេយ្យភាពជាមូលដ្ឋានសម្រាប់កសាងសង្គមមួយប្រកបដោយចំណេះដឹង និងជំនាញ។ វិស័យអប់រំ និងរៀបចំនូវក្របខណ្ឌធានាគុណភាពទូទាំងវិស័យដោយផ្អែកលើការសិក្សារៀនសូត្រ និងការផ្ដល់សេវាតាមស្តង់ដារឆ្លើយតបទៅ និងតម្រូវការរបស់កុមារ សហគមន៍ នឹងទីផ្សារការងារ។

**ខ. បេសកកម្ម**

ក្រសួងអប់រំ យុវជន និងកីឡា គឺបានកសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព នឹងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែកដើម្បីកសាងសង្គមកម្ពុជាឱ្យរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ ផ្អែកលើចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងបន្តផ្ដល់អាទិភាពខ្ពស់ដល់ការផ្ដល់សេវាអប់រំមូលដ្ឋានប្រកបដោយ សមធម៌ និងមានគុណភាពខ្ពស់ ដោយផ្ដោតលើការយកចិត្តទុកដាក់ដ៏ខ្ពស់ផងដែរទាំងលើការពង្រីកការអប់រំកុមារតូច ការបង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាប្រកបដោយគុណភាព ព្រមទាំងការពង្រីកការងារអប់រំក្រៅប្រព័ន្ធ និងការអប់រំបច្ចេកទេសដើម្បីឆ្លើយតបទៅ និងតម្រូវការទីផ្សារការងារក្នុងប្រទេសក្នុងតំបន់ និងលើសាកលលោក។

ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា នឹងការរីកចម្រើនក្នុងតំបន់ នឹង

សកលលោក។ បច្ចុប្បន្ននេះក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយលោក **ហង់ជួន ណារ៉ុន** ដែលលោកបានចូលកាន់តំណែងជារដ្ឋមន្ត្រីតាំងពីឆ្នាំ២០១៣។

**គ. គោលដៅ**

រដ្ឋាភិបាល មានគោលដៅប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមដែលផ្អែកលើចំណេះដឹង ដូច្នេះ ការកែលម្អគុណភាពអប់រំ គឺចាំបាច់ដើម្បីសម្រេចគោលដៅនេះ។ គុណភាពអប់រំ គឺជាកត្តាសំខាន់ក្នុងការធានាថា សិស្សានុសិស្សត្រូវបានបំពាក់ដោយចំណេះដឹងនិងជំនាញអនុវត្តជាក់ស្តែងដែលអាចប្រកួតប្រជែងជាមួយ នឹងស្តង់ដារតំបន់និងអន្តរជាតិ។ ប៉ុន្មានឆ្នាំមកនេះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវកំណែទម្រង់ នឹងវិធីសាស្ត្រជាច្រើន ដោយផ្តោតលើវិស័យផ្សេងៗគ្នា ដូចជាគុណភាពនៃការបង្រៀន នឹងការសិក្សា ហេដ្ឋារចនាសម្ព័ន្ធ នឹងការគ្រប់គ្រង។

គោលដៅអប់រំជាតិ គឺការកសាងមនុស្សពេញលេញដែលមានការរីកចម្រើនលូតលាស់គ្រប់ផ្នែកឱ្យព្រមៗគ្នា ដោយតុល្យភាពរវាងប្រាជ្ញាស្មារតី សញ្ចេតនា និងរូបរាងកាយពោល គឺពលរដ្ឋដែលមានលក្ខណៈថ្លៃថ្នូរ មានចំណេះដឹង មានបំណិនក្នុងវិជ្ជាជីវៈ មានបទពិសោធន៍ និងសីលធម៌ល្អដោយចេះអធ្យាស្រ័យ សហការប្រកបដោយសាមគ្គីភាព ស្មារតីឯកភាពជាតិមានមនៈសិការជាតិ ស្រឡាញ់យុត្តិធម៌ មានការគោរពច្បាប់ យល់ដឹងពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ចេះថែរក្សាការពារបរិស្ថាន ចេះផ្សព្វផ្សាយនិងលើកកម្ពស់តម្លៃវប្បធម៌ អរិយធម៌ជាតិ ម្ចាស់ការក្នុងទំនុកចិត្តលើខ្លួនឯងចេះដោះស្រាយបញ្ហាក្នុងជីវិតរស់ និងចេះច្នៃប្រឌិត ចេះធ្វើពលកម្ម មានស្មារតីទំនួលខុសត្រូវខ្ពស់ មានសមត្ថភាពក្នុងការកសាងសុខមាភាពក្នុងគ្រួសារ ហើយចូលរួមយ៉ាងសកម្មក្នុងការបង្រួបបង្រួមជាតិ នឹងស្តារអភិវឌ្ឍមាតុភូមិជាទីស្នេហារបស់ខ្លួនដោយផ្អែកលើស្មារតីប្រជាធិបតេយ្យសេរីបហុបក្ស។

គោលនយោបាយយុទ្ធសាស្ត្រទាំងបួនរបស់ក្រសួងអប់រំ យុវជន និងកីឡារួមមាន៖

- សកម្មភាពអប់រំចំណេះទូទៅ ៩ឆ្នាំអភិវឌ្ឍ អក្ខរកម្មវិជ្ជាជីវៈ និងបំពេញវិជ្ជា
- ទំនើបកម្ម និងកំណែលម្អគុណភាពអប់រំ តាមរយៈកំណែទម្រង់ប្រកបដោយប្រសិទ្ធិភាព
- ការផ្សាភ្ជាប់ការអប់រំទៅ និងតម្រូវការទីផ្សារ និងពលកម្មសង្គម
- ការស្តារ និងអភិវឌ្ឍន៍យុវជន និងកីឡា។

ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍជាតិ ប្រែក្លាយទៅជាប្រទេសកម្ពុជាឱ្យមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ នឹងជាប្រទេសអភិវឌ្ឍចំណូលខ្ពស់ឆ្នាំ២០៥០ កម្ពុជាត្រូវមានធនធានមនុស្សដែលមានសម្បទាទាំង៥រឹងមាំ គឺចំណេះសម្បទា បំណិនសម្បទា កាយសម្បទា ចរិយាសម្បទា និងស្មារតីស្នេហាជាតិសម្បទា។ នេះបើតាមសេចក្តីប្រកាសរបស់ក្រសួងអប់រំ នាថ្ងៃទី ៤ ខែកក្កដា។ ក្រសួងអប់រំ លើកឡើងថា សម្បទាទាំង៥នេះ អាចសម្រេចបាន ទាល់តែមានការចូលរួមដោយស្មារតីទទួលខុសត្រូវ របស់មហាជនកម្ពុជាទាំងអស់ កន្លងមកលោក **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួង ស្តីពីសុខភាពសិក្សា ធ្លាប់បាននិយាយថា ដើម្បីឱ្យធនធានមនុស្សទាំងអស់ អាចមានលទ្ធភាពក្លាយជាពលរដ្ឋសកម្មរបស់ជាតិ និងពលរដ្ឋសកលបាន លុះត្រាតែពួកគេមានសុខភាពល្អ។ លោកបានបន្ថែមថា មនុស្សអាចមានសុខភាពល្អបានទាល់តែពួកគេស្គាល់ពីតម្លៃសុខភាព និងយល់ច្បាស់ពីវិធានថែរក្សាសុខភាពខ្លួនឯង។ លោករដ្ឋមន្ត្រីក្រសួងអប់រំក៏ប្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីប្រតិបត្តិគ្រប់ផ្នែក យកចិត្តទុកដាក់អនុវត្តតាមផែនការប្រតិបត្តិ១០ឆ្នាំ

របស់ខ្លួនដោយបន្ទី និងបញ្ចូលជាផែនការប្រតិបត្តិប្រចាំឆ្នាំ តាមអង្គភាពរៀងខ្លួន។ ជាពិសេសត្រូវបំពេញរបាយការណ៍បញ្ជូនទៅលេខាធិការដ្ឋានឱ្យបានទាន់ពេលវេលា ដើម្បីអាចមានលទ្ធភាពដោះស្រាយបញ្ហានានាដែលអាចកើតជាយថាហេតុដែលរំខានដល់សុខភាពប្រជាជនទាំងអស់។

❖ <u>គោលដៅវិស័យអប់រំកាយនិងកីឡា</u>

វត្ថុបំណងនៃកម្មវិធីអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា គឺអភិវឌ្ឍការងារអប់រំកាយ និងកីឡា ឱ្យទៅជាចំណុចស្នូលនៃកំណែទម្រង់ និងលើកកម្ពស់សុខភាព សមត្ថភាព ជំនាញបច្ចេកទេសអប់រំកាយ និង កីឡារបស់សិស្សនិស្សិត យុវជន និងមហាជន ប្រកបដោយគុណភាព និងសមិទ្ធផលខ្ពស់ក្នុងការប្រកួតជាលក្ខណៈជាតិ និងអន្តរជាតិព្រមទាំងចូលរួមអភិវឌ្ឍសង្គម វប្បធម៌ និងសេដ្ឋកិច្ចជាតិ។ ការឆ្លើយតបទៅ នឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

**គោលនយោបាយទី ១** ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

- ពង្រឹង នឹងពង្រីកហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទនិងគ្រប់កម្រិត
- ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធកីឡារៀបចំបាននៅឆ្នាំ២០១១
- សេចក្ដីណែនាំស្ដីពីការរៀបចំទីលានកីឡាតាមគ្រឹះស្ថានសិក្សាកែលម្អបាននៅឆ្នាំ២០១១
- សារសម្រេចស្ដីពីការចងក្រងក្លឹប ឬសមាគមកីឡារៀបចំបាននៅឆ្នាំ២០១១
- លិខិតបទដ្ឋានស្ដីពី ការបង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់ហាត់ប្រាណដើម្បីសុខភាព រៀបចំបាននៅឆ្នាំ២០១២
- កម្មវិធីបណ្ដុះបណ្ដាលគ្រូអប់រំកាយ និងកីឡាកម្រិតមូលដ្ឋាន កែលម្អបាននៅឆ្នាំ២០១២
- កម្មវិធីសិក្សាអប់រំកាយ និងកីឡាសម្រាប់គ្រឹះស្ថានបឋម នឹងមធ្យមសិក្សា រៀបចំបាននៅឆ្នាំ២០១២
- សេចក្ដីណែនាំការបង្កើតសមាគមកីឡានៅក្នុងគ្រឹះស្ថានបឋមនិងមធ្យមសិក្សារៀបចំបាននៅឆ្នាំ២០១២
- ឯកសារស្ដីពីអត្តសញ្ញាណក្បាច់គុនបុរាណខ្មែររៀបចំបាននៅឆ្នា ២០១៣។

**គោលនយោបាយទី ២** ៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ

- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពកម្មវិធីអប់រំកាយ និងកីឡា
- កម្រិតរបបឧបត្ថម្ភ និងអាហារបំប៉នសម្រាប់កីឡាករជម្រើសជាតិ រៀបចំបាននៅឆ្នាំ២០១២
- កម្មវិធីហ្វឹកហាត់កីឡា កែលម្អបាននៅឆ្នាំ២០១២
- លិខិតបទដ្ឋានដើម្បីបង្កើតកម្មវិធីវេជ្ជសាស្ត្រកីឡា រៀបចំបាននៅឆ្នាំ២០១៣
- កំណែទម្រង់ប្រព័ន្ធនៃការប្រកួតកីឡាគ្រប់ប្រភេទ និងគ្រប់កម្រិត រៀបចំបាននៅឆ្នាំ២០១៣
- លើកកម្ពស់ការយល់ដឹង និងគាំទ្រអំពីសារៈសំខាន់របស់ការងារអប់រំកាយ និងកីឡា
- គោលនយោបាយជាតិស្ដីពីកីឡាបានរៀបចំនៅឆ្នាំ២០១១។

❖ <u>សូចនាករ និងចំណុចដៅ</u>

- សមាគម ឬក្លឹបកីឡាដែលត្រូវចូលរួមប្រកួតមានចំនួន ២៥០ ទៅ៣០០ ក្នុងមួយឆ្នាំ
- ទីលានកីឡាចំនួន ២០ ត្រូវបានកែលម្អត្រឹមឆ្នាំ២០១៣

- ទីលានកីឡានៅតាមគ្រឹះស្ថានសិក្សាបឋមសិក្សា និងមធ្យមសិក្សាចំនួន ១៦៥ ត្រូវបានកែលម្អនៅឆ្នាំសិក្សា ២០១៣-២០១៤។
- អភិវឌ្ឍសមាគមកីឡាសិស្ស-និស្សិតចំនួន ១២៥ នៅឆ្នាំសិក្សា ២០១៣-២០១៤
- គ្រូអប់រំកាយ និងកីឡាចំនួន ១៥០ នាក់ត្រូវបានបណ្តុះបណ្តាលក្នុងមួយឆ្នាំ
- កីឡាករជម្រើសជាតិចំនួន ៣៥០ នាក់ត្រូវបានប្រមូលផ្តុំក្នុងមួយឆ្នាំ
- ទស្សនាវដ្តីកីឡាត្រូវបានផ្សព្វផ្សាយជារៀងរាល់ខែ

❖ **<u>កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)</u>**

- ការអភិវឌ្ឍន៍សមាគមនកីឡាមហាជន
- កែលម្អទីលានកីឡា
- ត្រួតពិនិត្យតាមដានការកែលម្អទីលានកីឡា នឹងអភិវឌ្ឍសមាគមកីឡា
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រង គ្រូបង្វឹក ចៅក្រម អាជ្ញាកណ្តាលថ្នាក់ជាតិក្នុងមជ្ឈដ្ឋាន មហាជនក្នុងប្រទេស និងក្រៅប្រទេស
- បំពាក់សម្ភារៈ និងឧបករណ៍កីឡានៅតាមសមាគម និងក្លឹបកីឡាមហាជន
- អភិវឌ្ឍគោលនយោបាយកីឡាមហាជន
- រៀបចំការប្រកួតកីឡាមហាជនជម្រើសជើងឯកភូមិភាគ នឹងជម្រើសជើងឯកថ្នាក់ជាតិ
- ស្រាវជ្រាវចងក្រងឯកសារកីឡាទំនើប កីឡាប្រពៃណី នឹងទិន្នន័យអ្នកលេងកីឡាដើម្បីទាំងអស់គ្នា "ដើម្បីសុខភាព"
- ការអភិវឌ្ឍសមាគមកីឡាសិស្ស-និស្សិត
- ជួសជុលទីលានកីឡាក្នុងគ្រឹះស្ថានបឋមសិក្សានិងមធ្យមសិក្សា
- អភិវឌ្ឍសមាគមកីឡាក្នុងជួរសិស្ស-និស្សិត
- បំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡា និងគ្រូចំណេះទូទៅ ដែលទទួលបន្ទុកការងារ អប់រំកាយនឹងកីឡានៅក្នុងគ្រឹះស្ថានមធ្យមសិក្សា និងសាលាគរុកោសល្យរាជធានី ខេត្ត នឹងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- ពិនិត្យតាមដាន នឹងវាយតម្លៃការជួសជុលទីលានកីឡា ការអភិវឌ្ឍន៍សមាគមកីឡា នឹងការបំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡា
- អភិវឌ្ឍអង្គភាព សហព័ន្ធ សមាគម និងក្លឹបកីឡានៅក្នុងគ្រឹះស្ថានសិក្សា
- អភិវឌ្ឍគោលនយោបាយកីឡានៅក្នុងគ្រឹះស្ថានសិក្សា
- រៀបចំការប្រកួតកីឡាសិស្ស និស្សិតនៅគ្រប់កម្រិតសិក្សា
- រៀបចំកម្មវិធីហ្វឹកហាត់ដល់អត្តពលិកដែលជាសិស្ស-និស្សិត (ក្នុង និងក្រៅប្រទេស)
- បំពាក់សម្ភារៈ នឹងឧបករណ៍កីឡានៅតាមគ្រឹះស្ថានសិក្សា
- ស្រាវជ្រាវឱ្យសមស្របនៅគ្រឹះស្ថានបឋមសិក្សា នឹងមធ្យមសិក្សា
- រៀបចំកម្មវិធីសិក្សាអប់រំកាយ និងកីឡាសម្រាប់បឋមសិក្សា នឹងមធ្យមសិក្សា
- ការបណ្តុះបណ្តាល នឹងស្រាវជ្រាវអប់រំកាយ និងកីឡា

- បំប៉នគ្រូទទួលបន្ទុកការងារអប់រំកាយ និងកីឡាតាមកម្រង សាលាគរុកោសល្យនិវិក្រឹតការាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងបំប៉នជំនាញថៅក្រមអាជ្ញាកណ្តាល
- បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាកម្រិតមូលដ្ឋាន
- ស្រាវជ្រាវ បកប្រែ ចងក្រង រក្សាឯកសារស្តីពីវិទ្យាសាស្ត្រអប់រំកាយ និងកីឡា
- ត្រួតពិនិត្យ នឹងតាមដានលើវិធីសាស្ត្របង្ហាត់បង្រៀនអប់រំកាយ និងកីឡា
- កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- ការអភិវឌ្ឍន៍កីឡាកម្រិតខ្ពស់
- ប្រមូលផ្តុំគ្រូបង្វឹក អនុរក្ស និងកីឡាករជម្រើសជាតិ ហាត់ហ្វឹកហ្វឺនត្រៀមចូលរួមការ ប្រកួតលក្ខណៈអន្តរជាតិ
- បំប៉នសមត្ថភាពគ្រូបង្វឹក អនុរក្ស នឹងកីឡាករជម្រើសជាតិ
- បំពាក់សម្ភារៈ នឹងឧបករណ៍បច្ចេកទេសហាត់ជំនួយសាច់ដុំ ដើម្បីបង្កើនប្រសិទ្ធភាពកម្លាំងកាយ ថាមពលមាំមួន បច្ចេកទេសល្អ នឹងសមិទ្ធផលកើនឡើង
- រៀបចំលិខិតបទដ្ឋាន ចងក្រងឯកសារកីឡាគ្រប់ប្រភេទតម្កល់ទុកក្នុងបណ្ណាល័យ
- និពន្ធ រៀបរៀង និងបោះពុម្ពទស្សនាវដ្តីកីឡា ចែកជូនតាមបណ្តារាជធានី-ខេត្ត។

❖ **<u>កម្មវិធីចំណាយមូលធន</u>**

- សាងសង់សាលដំបូលទូកសម្រាប់ហ្វឹកហាត់កីឡាបាល់ទះ នឹងសាងសង់ទីលានកីឡាអត្តពលកម្មសិប្បនិម្មិតនៅក្នុងពហុកីឡាដ្ឋានជាតិ
- សាងសង់អគារសិក្សា អន្តេវាសិកដ្ឋាន និងសាលសម្រាប់ហាត់កីឡា នៅវិទ្យាស្ថានជាតិអប់រំ កាយ និងកីឡា
- កសាងទីលានកីឡាក្នុងគ្រឹះស្ថានសិក្សា (កីឡាបាល់បោះ និងបាល់ទាត់)
- សាងសង់មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាឱ្យបានត្រឹមត្រូវតាមនិយាមបច្ចេកទេស នឹងបង្កើតមជ្ឈមណ្ឌលភូមិភាគ។

❖ **<u>ការពិនិត្យតាមដាននិងការគ្រប់គ្រងកម្មវិធី</u>**

កម្មវិធីអភិវឌ្ឍវិស័យអប់រំកាយ និងកីឡាត្រូវគ្រប់គ្រង និងពិនិត្យតាមដាន តាមរយៈប្រធាន អនុកម្មវិធីនីមួយៗដូចជា នាយកដ្ឋានអប់រំកាយ និងកីឡា នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា និងមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា។ ការងារនេះមានការសម្របសម្រួលរវាងប្រធានអនុកម្មវិធីនៃនាយកដ្ឋានពាក់ព័ន្ធ ដើម្បីធានាឱ្យការពិនិត្យតាមដានមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ការពិនិត្យតាមដានកម្មវិធីក៏មានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដែលពាក់ព័ន្ធការងារអប់រំកាយ និងកីឡានានាៗទាំងផ្នែកបច្ចេកទេសនិងថវិកា ដើម្បីរួមចំណែកអភិវឌ្ឍការងារអប់រំកាយ និងកីឡាគ្រប់ប្រភេទ និងគ្រប់លំដាប់ថ្នាក់។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

#### ក.រចនាសម្ព័ន្ធគ្រប់គ្រង




#### ខ. តួនាទីគណៈគ្រប់គ្រង

ប៉ុន្មានឆ្នាំមកនេះ គោលនយោបាយ និងបទប្បញ្ញត្តិត្រូវបានអនុវត្តដើម្បីបង្កើនគុណភាពអប់រំភាពងាយស្រួល ប្រសិទ្ធភាព បរិយាប័ន្ន និងតម្លាភាព។ គោលនយោបាយ និងបទប្បញ្ញត្តិទាំងនោះរួមមានផែនការយុទ្ធសាស្ត្រ ដែលអប់រំនៅឆ្នាំ២០១៩-២០២៣ ផែនទីដែលបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ ២០៣០ គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤) គោលនយោបាយស្តីពី សាលារៀនជំនាន់ថ្មី គោលនយោបាយស្តីពីការអប់រំប្រកបដោយបរិយាប័ន្ន និងគោលនយោបាយជាតិស្តីពី ការសិក្សាពេញមួយជីវិត។ ការអភិវឌ្ឍន៍ធនធានមនុស្ស មានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលដៅសេដ្ឋកិច្ចឆ្នាំ២០៣០ ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមមានកម្រិត។ រដ្ឋាភិបាលបានយកចិត្តទុកដាក់លើការអប់រំ
និងការបណ្តុះបណ្តាលដើម្បីបង្កើនធនធានមនុស្ស។ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល អាចមើលឃើញនៅក្នុងការចំណាយលើការអប់រំប្រចាំឆ្នាំ។ នៅឆ្នាំ២០២១ ការចំណាយលើវិស័យអប់រំមានចំនួន៨១០លានដុល្លារអាមេរិកនិង៧៩៧លានដុល្លារសម្រាប់ឆ្នាំ២០២២។ រដ្ឋាភិបាលមានគោលដៅប្រែក្លាយប្រទេសកម្ពុជាទៅ

ជាសង្គមដែលផ្អែកលើចំណេះដឹង ដូច្នេះការកែលម្អគុណភាពអប់រំ គឺចាំបាច់ដើម្បីសម្រេចគោលដៅនេះ។ គុណភាពអប់រំ គឺជាកត្តាសំខាន់ក្នុងការធានាថាសិស្សានុសិស្ស ត្រូវបានបំពាក់ដោយចំណេះដឹង ជំនាញអនុវត្តជាក់ស្តែងដែលអាចប្រកួតប្រជែងជាមួយ និងស្តង់ដារតំបន់និងអន្តរជាតិ។ ប៉ុន្មានឆ្នាំមកនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកំណែទម្រង់ និងវិធីសាស្ត្រជាច្រើនដោយផ្តោតលើវិស័យផ្សេងៗគ្នាដូចជាគុណភាពនៃការបង្រៀន និងការសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រង។

កំណត់នយោបាយអប់រំ យុវជន និងកីឡាសំដៅធានាការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។ ក្រសួងអប់រំ យុវជន និងកីឡាមានមុខងារ និងភារកិច្ចដូចតទៅ៖

- កសាងនីតិក្រមសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- កសាងផែនការអនុវត្ត ពិនិត្យតាមដាន នឹងវាយតម្លៃនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រមទាំងលើកទិសដៅ នឹងវិធានការកែលម្អជាបន្តបន្ទាប់តាមគ្រប់មុខជំនាញ
- លើកកម្ពស់គុណភាពវិស័យអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅ នឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិនិងអន្តរជាតិដើម្បីកសាងសមត្ថភាពខាងចំណេះដឹងចំណេះធ្វើសីលធម៌ នឹងចេះរួមរស់ជាមួយគ្នា
- តម្រង់ទិសវិជ្ជាជីវៈបំណិនជីវិត នឹងបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា
- លើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដោយធានាសមធម៌ និងបរិយាបទ
- អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកសហគ្រិនភាព និងអប់រំបច្ចេកទេសក្នុងតំបន់
- សិក្សាលើសំណើរបង្កើត បើក បិទ រំលាយបញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយ គ្រឹះស្ថានឧត្តម សិក្សាសាធារណៈ
- សិក្សាលើសំណើរទទួលស្គាល់ការបង្កើត បើក បិទ រំលាយបញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយ គ្រឹះស្ថានឧត្តមសិក្សាឯកជន
- លើកកម្ពស់ការស្រាវជ្រាវ និងបច្ចេកវិទ្យាព័ត៌មានដើម្បីអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- គ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា នឹងឯកសារពាក់ព័ន្ធនិងការបង្រៀន និងរៀនគ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ
- ពិនិត្យលើការផ្តល់ បដិសេធ ដកហូតវិញ្ញាបនបត្រឬសញ្ញាបត្រ និងវាយតម្លៃកម្រិតវិញ្ញាបនបត្រ ឬសញ្ញាបត្រចេញដោយគ្រឹះស្ថានសិក្សានានាទាំងក្នុងទាំងក្រៅប្រទេស
- ផលិត នឹងត្រួតពិនិត្យការផ្សព្វផ្សាយព័ត៌មានអប់រំ ការផ្សាយពាណិជ្ជកម្មសិក្សាតាមគ្រប់រូបភាពពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- អភិវឌ្ឍការងារយុវជន និងការងារអប់រំកាយ និងកីឡា ដោយកំណត់វិធានគ្រប់គ្រង អប់រំ បណ្តុះបណ្តាល នឹងបំប៉នបច្ចេកទេស
- បង្កើនការយល់ដឹងអំពីវប្បធម៌ជាតិ និងវប្បធម៌អន្តរជាតិ
- គ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ នឹងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង អប់រំ យុវជន និងកីឡា

- ពិនិត្យនិងផ្តល់យោបល់លើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**គ. ភារកិច្ចគណគ្រប់គ្រង**

ដើម្បីគ្រប់គ្រងសាលារៀនឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំបានផ្តោតទៅលើនាយកសាលារៀនមានតួនាទីជាទីជាទីប្រឹក្សាគរុកោសល្យអធិការអចិន្ត្រៃយ៍ មន្ត្រីរដ្ឋបាល អ្នកចរចារ អ្នកអប់រំ អ្នកផ្តល់សេវាកម្ម អ្នកពិគ្រោះយោបល់ ជាភ្នាក់ងារអភិវឌ្ឍសហគមន៍ និងជាអាជ្ញាធរអប់រំលើការងារគ្រប់គ្រងរដ្ឋបាល ការងារគ្រប់គ្រងការៀននឹងបង្រៀន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានភារកិច្ចដូចខាងក្រោម៖

❖ <u>ការគ្រប់គ្រងការងាររដ្ឋបាល៖</u>

- កសាងចក្ខុវិស័យ បេសកម្ម ផែនការសម្មភាព ដើម្បីអភិវឌ្ឍសាលារៀន នឹងផែនទីសិក្សា
- រៀបចំ និងពិនិត្យសម្រេចលើរចនាសម្ព័ន្ធគ្រប់គ្រង ការវិភាគមុខងារ និងចុះហត្ថលេខាលើលិខិតបទដ្ឋានផ្សេងៗរបស់អង្គភាព
- ផ្សព្វផ្សាយ និងផ្តល់ដំណឹងឱ្យមាតាបិតា ឬអាណាព្យាបាលនាំកូនមកចុះឈ្មោះចូលរៀន
- ដឹកនាំការប្រជុំការងាររបស់សាលារៀន នឹងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត
- រៀបចំ នឹងរក្សាទុកលិខិតបទដ្ឋានគតិយុត្តឱ្យមានសណ្តាប់ធ្នាប់
- ធានាឱ្យសាលារៀនបំពេញបាននូវការផ្តល់សេវាសាធារណៈ
- ពិនិត្យតាមដាន និងវាយតម្លៃការងារយ៉ាងល្អិតល្អន់ ដោយមានវិធានការអនុវត្ត
- រៀបចំក្រុមប្រឹក្សា និងគណៈកម្មការជានារបស់អង្គភាពដូចជា៖ ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន គណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការសុខភាពសិក្សា គណៈកម្មការមគ្គុទេសក៍អាជីព និងប្រឹក្សាយោបល់ គណៈកម្មការស្ទែម (STEM) ជាដើម
- ចេញលិខិតបញ្ជាក់ការសិក្សា និងប័ណ្ណសម្គាល់ខ្លួនឱ្យគ្រូ នឹងសិស្សរៀបចំទីចាត់ការរក្សាសណ្តាប់ធ្នាប់នឹងវិន័យក្នុងកាសាលារៀន
- ពិនិត្យ និងសម្រេចលើការរៀបចំបទបញ្ញត្តិផ្ទៃក្នុងរបស់សាលារៀន ការជ្រើសរើសសិស្សទទួលបានអាហារូបករណ៍និងផ្ទេរការសិក្សាចេញ និងចូលរបស់សិស្ស
- រៀបចំសៀវភៅសម្រាប់កត់ត្រាលិខិតចូល នឹងលិខិតចេញ និងរៀបចំកំណត់ហេតុនៅពេលមានការប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋាន ឬប្រជុំនានានៅក្នុងសាលារៀន
- ចូលរួមប្រជុំការងារជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកខណ្ឌ មន្ទីអប់រំយុវជន និងកីឡារាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់
- គ្រប់គ្រងការងារយុវជន កីឡា និងសិល្បៈ និងចូលរួមសកម្មភាពនានាក្នុងការងារសង្គម
- រៀបចំបរិស្ថានឱ្យមានអនាម័យ សោភណ្ឌភាព នឹងអត្តសញ្ញាណជាតិក្នុងសាលារៀន(ទីធ្លាចំណត ថ្នាក់រៀន បង្គន់ តូបលក់នំចំណី/អាហាដ្ឋាន ដើមឈើធ្វើម្លប់ សួនច្បារ សួនជីវចម្រុះ)
- ធ្វើទំនាក់ទំនងជាមួយមាតាបិតា អ្នកណាព្យាបាល សហគមន៍ សប្បុរសជន ដៃគូអភិវឌ្ឍវិស័យឯកជន

- បូកសរុបរបាយការណ៍ការងារ និងលទ្ធផលសិក្សាប្រចាំឆ្នាំជូនទៅអង្គភាពពាក់ព័ន្ធ
- បំពេញភារកិច្ចចាំបាត់តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ

❖ **ការគ្រប់គ្រងការងាររៀន នឹងបង្រៀន(បច្ចេកទេស)៖**

- ដឹកនាំ នឹងគ្រប់គ្រងការរៀន នឹងបង្រៀន នឹងជាទីប្រឹក្សាគរុកោសល្យ
- ពិនិត្យ នឹងសម្រេចលើការរៀបចំកាលវិភាគ នឹងបែងចែកកម្មវិធីសិក្សាសម្រាប់ការបង្រៀន នឹងរៀនស្រប តាមនិយាមនិងស្តង់ដា
- ជំរុញឱ្យមានដំណើរការថ្នាក់រៀនឆ្លាតវៃ( Smart Classroom ) និងតាមបែបឌីជីថល
- ជំរុញ នឹងតាមដានការប្រជុំបច្ចេកទេស ប្រជុំគរុកោសល្យ ការធ្វើថ្នាក់និទស្សន៍ នឹងផ្សព្វផ្សាយសារណែនាំនានា នឹងតាមដានការអនុវត្តកម្មវិធីសិក្សាលម្អិតគ្រប់កម្រិតថ្នាក់តាមមុខវិជ្ជា
- ជំរុញឱ្យមានការសិក្សាស្រាវជ្រាវមេរៀនលើមុខវិជ្ជាឯកទេស វិធីសាស្ត្របង្រៀនថ្មីៗ នឹងការផលិតសម្ភារឧបទេសតាមរយៈបណ្ណាល័យ Website Online Internet ICT…
- ជំរុញឱ្យដំណើរការនៅក្នុងបន្ទប់ពិសោធន៍ បន្ទប់សុខភាព បន្ទប់ពហុបំណង កុំព្យូទ័រ បណ្ណាល័យ បន្ទប់ប្រឹក្សា បន្ទប់ភាសាបរទេស រោងជាង សិល្បៈ និងទីលានកីឡា
- ពិនិត្យ និងសម្រេចលើវិញ្ញាសាតាមកម្រិតថ្នាក់ តាមមុខវិជ្ជាសម្រាប់ការប្រឡងនានា
- ចលនាភូមិស្អាត ហូបស្អាត ផឹកស្អាតរស់នៅស្អាត សុខភាពរបស់សិស្សានុសិស្ស នឹងគ្រូបង្រៀន
- ផ្គត់ផ្គង់សៀវភៅសិក្សាគោល ឯកសារ និងសម្ភារផ្សេងៗ
- រៀបចំយន្តការជួយគ្រូបង្រៀនចេញថ្មី និងពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈប្រចាំ
- ជំរុញណែនាំ នឹងពិនិត្យតាមដានសិស្សានុសិស្សឱ្យរៀននៅផ្ទះ នឹងនៅក្លឹបសិក្សា
- ត្រួតពិនិត្យវត្តមានសិស្ស វត្តមានគ្រូបង្រៀន នឹងការគ្រប់គ្រងសាលារៀន
- រៀនសូត្រ នឹងដកបទពិសោធន៍ពីការអនុត្តន៍នៃការគ្រប់គ្រងតាមសាលារៀន
- ប្រើលទ្ធផលតេស្ត/ប្រឡង ដើម្បីរៀបចំផែនការកែកម្អសាលារៀនរយៈពេលខ្លី មធ្យម នឹងវែង
- រៀបចំវិធានការនិងយន្តការ ដើម្បីជួយសិស្សរៀនយើងត្រូវ៖
  - ប្រើប្រាស់សន្លឹកកិច្ចការស្វ័យសិក្សាតាមរយៈការរៀន ជាឯកសារហ្វឹកហាត់ប្រចាំថ្ងៃ ដើម្បីឱ្យសិស្សមានឱកាសស្រាវជ្រាវមេរៀនបន្ថែមនៅផ្ទះ
  - ជំរុញគ្រូបង្រៀនដាក់កិច្ចការផ្ទះឱ្យសិស្ស និងកែកិច្ចការសិស្សឱ្យបានច្បាស់លាស់
  - រៀបចំក្លឹបសិក្សាតាមមុខវិជ្ជា សម្រាប់ជួយសិស្សរៀនយឺត ពិសេសលើមេរៀនដែលសិស្សទទួលបានលទ្ធផលមិនសូវល្អ
  - រៀបចំ នឹងពង្រឹងក្រុមបច្ចេកទេសតាមមុខវិជ្ជានៅតាមសាលារៀន ដើម្បីរិះរកវិធីជួយសិស្ស
  - សិក្សាស្រាវជ្រាវលើកត្តាដែលនាំឱ្យសិស្សរៀនយឺតតាមមុខវិជ្ជា
  - ផ្តល់ថវិកាបន្ថែមសម្រាប់គាំទ្រដល់សកម្មភាពបង្រៀន និងរៀនដើម្បីជួយសិស្សរៀនយឺតឱ្យចំគោលដៅ
  - អញ្ជើញមាតាបិតាសិស្ស សហគមន៍ នឹងអាជ្ញាធរមូលដ្ឋានចូលរួមពិភាក្សាជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សក្នុងកិច្ចប្រជុំប្រចាំខែ

- បង្កើន និងពង្រឹងការធ្វើអធិការកិច្ចនៅតាមសាលារៀន
  - រៀបចំផែនការអធិការកិច្ចថ្នាក់រៀនប្រចាំខែ នឹងចុះអធិការកិច្ចជួយគ្រូបង្រៀនឱ្យបានច្បាស់លាស់
  - ពិនិត្យតាមដាន នឹងពង្រឹងការអនុវត្តកម្មវិធីសិក្សា
  - ធ្វើធិការកិច្ចតាមមុខវិជ្ជា ដោយផ្តោតលើការអនុវត្តកម្មវិធីសិក្សា
  - ធ្វើអធិការកិច្ចដោយផ្តោតលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា។

**ជាអាជ្ញាធរអប់រំ៖** បើតាមប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ នាយកសាលារៀនជា ប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ប្រចាំភូមិសាស្ត្រសិក្សារបស់សាលានីមួយៗ។ ទន្ទឹមគ្នានេះដែរ នាយកសាលាក៏ជាអ្នកធានាទាក់ទងការងាររវាងសាលារៀន និងថ្នាក់លើ។ គាត់ជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ជាសិក្សា និងអត្ថបទផ្លូវការទាំងឡាយ ។ នាយកសាលា រៀនដឹកនាំ គ្រប់គ្រង សកម្មភាពក្នុងសាលារៀន និងធានាឱ្យបានប្រសិទ្ធភាពតាមគោលដៅអប់រំ ដែលបានគ្រោងទុក។ ជាពិសេស នាយកសាលារៀនទទួលខុសត្រូវទាំងស្រុង ចំពោះមុខសាលារៀន និងថ្នាក់លើ នូវរាល់អ្វីដែលកើតមានឡើង ក្នុងសមត្ថកិច្ចរបស់ខ្លួន។

**ជាមន្ត្រីរដ្ឋបាល៖** នាយកសាលារៀនជាអ្នកណែនាំ អនុវត្តរដ្ឋបាលសិក្សាទាំងអស់ក្នុងសាលារៀន ធានាធ្វើឱ្យសម្រេចគោលនយោបាយអប់រំ ដោយរិះរកគ្រប់មធ្យោបាយ នឹងវិធានការចាំបាច់ដើម្បីធ្វើឱ្យសកម្មភាពប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ប្រជាធិបតេយ្យ នឹងអភិបាលកិច្ចល្អ។

**ជាទីប្រឹក្សាគរុកោសល្យ៖** ក្នុងឋានៈជាគ្រូបង្រៀន និងគ្រូបង្រៀនមានបទពិសោធន៍ នាយកសាលារៀនមានសិទ្ធិអំណាចណែនាំ គរុកោសល្យដល់គ្រូបង្រៀនក្រោមឱវាទ នូវល្បិច និងគន្លឹះល្អៗនៃការបង្រៀន នាយកសាលារៀន និងអាចបំពេញភារកិច្ចនេះបានល្អ លុះត្រាណាជានិច្ចកាល ស្វ័យសិក្សា និងអភិវឌ្ឍ សម្បទាចិត្តគរុកោសល្យគ្មានឈប់ឈរ។ ម៉្យាងវិញទៀត គ្រូបង្រៀនតែងផ្តល់កិត្តិយស និងគោរពនាយកសាលារៀនណាដែលមានសម្បទា អាចធានាការរៀបចំគរុកោសល្យបានល្អ ។

**ជាអធិការអប់រំអចិន្ត្រៃយ៍៖** នាយកសាលារៀនមានសិទ្ធិត្រួតពិនិត្យ និងជួយកែលម្អសកម្មភាពអប់រំគ្រប់ផ្នែក ជាពិសេសសកម្មភាពបង្រៀន និងរៀន ។ ក្រោយពេលអធិការកិច្ចម្តងៗ បន្ទាប់ពីការសំណេះសំណាលស្វែងយល់ពីគ្នាទៅវិញទៅមក លោកអធិការអប់រំតែងធ្វើការណែនាំមួយចំនួនដើម្បីឱ្យមានការអភិវឌ្ឍ ។ នាយកសាលារៀនដែលជាអធិការអប់រំអចិន្ត្រៃយ៍ បន្តណែនាំឱ្យអនុវត្តជួយកែលម្អ និងវាយតម្លៃដើម្បីឱ្យបានសម្រេចទៅតាមស្មារតីនៃការណែនាំរបស់លោកអធិការអប់រំ ។

**ជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍៖** នាយកសាលារៀន គឺជាភ្នាក់ងារដ៏សំខាន់ នឹងចាំបាច់នៃការអភិវឌ្ឍន៍សហគមន៍ ជាពិសេសអភិវឌ្ឍចិត្តគំនិត និងស្មារតី។

## ៣.២ មូលហេតុដែលបណ្តាលឱ្យមានការសិក្សាពីចម្ងាយ

នាពេលបច្ចុប្បន្ននេះការសិក្សាពីចម្ងាយពិតជាមានភាពទូលំទូលាយដោយសារមានការរីកចម្រើនទៅលើបច្ចេកវិទ្យា និងកម្មវិធីអប់រំដូចជា Zoom , Google Meet , Google Classroom។ល។ កម្មវិធីសិក្សាទាំងនេះ វាមានភាពងាយស្រួលដល់និស្សិត ដែលបានជួបនឹងបញ្ហាមួយចំនួនដែលធ្វើឱ្យពួកគេសម្រេចចិត្តជ្រើសរើសយកការសិក្សាពីចម្ងាយនេះ។ អ្នកខ្លះមានបញ្ហា ក្នុងគ្រួសារដែលមិនអាចឱ្យគាត់មករៀនដោយផ្ទាល់បាន អ្នកខ្លះទៀតគ្មានមធ្យោបាយសម្រាប់ធ្វើដំណើរមករៀន ឬមានទីលំនៅនៅឆ្ងាយពីសាលារៀនដែលជាហេតុធ្វើឱ្យពិបាកក្នុងការធ្វើដំណើរទៅមក។ ហើយបញ្ហាទាំងនោះរួមមានដូចខាងក្រោម៖

**៣.២.១ គ្រួសារ**

គ្រួសារក៏ជាមូលហេតុដែលធ្វើឱ្យមានការសិក្សាពីចម្ងាយដែរព្រោះពេលខ្លះនៅក្នុងគ្រួសារមានសមាជិកមួយចំនួនក៏មានបញ្ហាផ្សេងៗដែលធ្វើឱ្យមានការសិក្សាពីចម្ងាយដូច ឪពុកម្តាយ តាយាយពួកគាត់ឈឺចាស់ជរាដែលយើងមិនអាចទៅឆ្ងាយពីគាត់បាន ដូច្នេះហើយទើបធ្វើយើងសម្រេចចិត្តក្នុងការជ្រើសរើសការសិក្សាពីចម្ងាយ។

**៣.២.២ មធ្យោបាយ ឬយានជំនិះ**

និស្សិតមួយចំនួនមាន ទីលំនៅឆ្ងាយពីសាលាពិបាកធ្វើដំណើរមករៀន និងគ្មានលទ្ធភាពទិញម៉ូតូជិះមកសាលាមកសាលារៀន ទើបធ្វើឱ្យពួកគាត់ជ្រើសរើសការសិក្សាពីចម្ងាយជាមធ្យោបាយ ក្នុងការបន្តការសិក្សារបស់ពួកគាត់បានយ៉ាងងាយស្រួល។

**៣.២.៣ ខ្លួនឯង**

និស្សិតមួយចំនួនត្រូវបានរៀបការធ្វើឱ្យពួកគាត់គ្មានពេលគ្រប់គ្រាន់មករៀនដោយផ្ទាល់ទេព្រោះគាត់ត្រូវទទួលរងនៅកិច្ចផ្ទះសម្បែង មើលថែកូន រៀបចំទុកដាក់ផ្ទះសម្បែងឱ្យស្អាត ធ្វើម្ហូប ឬមានកិច្ចផ្សេងៗទៀតដែលជាហេតុធ្វើឱ្យពួកជ្រើសរើសការរៀនពីចម្ងាយជាពិសេស និស្សិតដែលមានផ្ទៃពោះ និងសម្រាលកូនរួច។ មួយវិញទៀតនិស្សិតមួយចំនួន គាត់មានភាពអៀនខ្មាស់មិនហ៊ាននិយាយច្រើន ឬផ្តល់ជាមតិយោបល់ឡើយទើបធ្វើឱ្យយកការរៀនពីចម្ងាយនេះ។

**៣.២.៤ ផ្ទះនៅឆ្ងាយពីសាលា**

និស្សិតមួយចំនួនមានការលំបាកក្នុងការធ្វើដំណើរមកសាលារៀនព្រោះមានទីលំនៅតាមតំបន់ដាច់ស្រយ៉ាល ផ្លូវស្ងាត់ ហើយណាមួយខ្លួនជាស្រីខ្លាចមានគ្រោះផ្សេងៗដែលកើតមានជាយថាហេតុ។ មួយវិញទៀតសម្រាប់និស្សិតមួយចំនួនជាប់រវល់ធ្វើការនៅឯស្រុកកំណើត ដែលធ្វើគាត់មករៀនផ្ទាល់ពុំបាន។ ក្រៅពីនេះនៅពេលរដូវភ្លៀងធ្លាក់កាន់តែពិបាកក្នុងការធ្វើដំណើរថែមទៀតផង ផ្លូវរអិល ឬក៏អាចមានគ្រោះទឹកជំនន់ នឹងគ្រោះថ្នាក់នាៗ។

**៣.២.៥ បញ្ហាផ្សេងៗ**

នៅក្នុងគ្រួសារមានធុរៈចាំបាច់ គ្រោះធម្មជាតិ គ្រោះទឹកជំនន់ ខ្វះសម្ភារៈសិក្សា ឬហេតុការណ៍ផ្សេងៗដែលបង្ករដល់ការរៀននៅក្នុងថ្នាក់ មានភាពរញ៉េរញ៉ៃក្នុងពេលរៀនជាដើម។

**៣.២.៦ សុវត្ថិភាពជាចម្បង**

តំបន់រស់នៅពុំមានសុវត្ថិភាព អសន្តិសុខសង្គម ក្មេងទំនើង ជាហេតុធ្វើឱ្យសិស្សខ្លាចក្នុងការធ្វើដំណើរមកសាលារៀនពិសេស គឺសិស្សស្រី។

ទោះបីជាការសិក្សាពីចម្ងាយទទួលបានការរៀនច្រើនពីសំណាក់និស្សិតក៏ដោយក៏ការសិក្សាពីចម្ងាយនេះក៏មានបញ្ហាមួយចំនួនតូចផងដែរ។ **ការរៀនតាមអ៊ីនធើណិតបង្កើតអារម្មណ៍នៃភាពឯកោ** គឺជាមូលហេតុមួយនៃភាពឯកោក្នុងសង្គម ដោយសារតែអ្នកមិនបានជួបគ្រូ និងមិត្តរួមថ្នាក់របស់អ្នកដោយផ្ទាល់។ ការរៀនតាមអ៊ីនធើណិតទាមទារការលត់ដំខ្លួន អ្នកសិក្សាត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ការតាំងចិត្តខ្ពស់។ **ការរៀនតាមអ៊ីនធើណិតទាមទារការបណ្តុះបណ្តាលបន្ថែមសម្រាប់គ្រូ** គ្រូបង្រៀនត្រូវស្វែងយល់ពីឌីជីថលការប្រើប្រាស់ដូចជា៖ ការវាយតម្លៃ ការបង្ហាញរូបភាព ល្បែង(Game) និងកម្មវិធីនានាក្នុងការបង្រៀន។ **ថ្នាក់អនឡាញងាយ នឹងមានបញ្ហាបច្ចេកទេស** ការសិក្សាតាមអ៊ីនធើណិត អាចជួបបញ្ហាដូចជា អ៊ីនធើណិត ឬអាចដាច់

ចរន្តអគ្គិសនី នឹងបញ្ហាផ្សេងៗ។ ការចំណាយពេលច្រើននៅមុខកុំព្យូទ័រ ឬទូរស័ព្ទ ការចំណាយពេលវេលាដ៏ច្រើនក្នុងការសិក្សានៅ នឹងមុខអេក្រង់កុំព្យូទ័រ និងទូរស័ព្ទអាចបង្កជាផលវិបាកដូចជា បញ្ហាភ្នែក សុខភាពឆ្អឹង ការថប់អារម្មណ៍ក៏អាចមាន។ **បញ្ហាអ៊ីនធើណិត** ប្រសិនបើអ្នកស្ថិតនៅក្នុងតំបន់មួយដែលមានការតភ្ជាប់អ៊ីនធើណិតលឿន និងមានស្ថិរភាពអ្នកសំណាងតែជាអកុសល អ្នកខ្លះមានការចូលប្រើប្រាស់អ៊ីនធើណិតមានកម្រិត។ ពួកគេត្រូវទៅកន្លែងដែលមានសេវាអ៊ីនធើណិត ឬប្រើWi-Fiសាធារណៈដែលមានការរអាក់រអួលខ្លាំង។ **ប្រសិទ្ធភាពនៃការគ្រប់គ្រងមានកម្រិត** ការរៀនតាមអ៊ីនធើណិតរួមបញ្ចូលការវាយតម្លៃ ដូចជានៅក្នុងថ្នាក់រៀនធម្មតាដែរ។ ទោះយ៉ាងណាក៏ដោយមិនមានគ្រូ ឬអ្នកត្រួតពិនិត្យមើលសិស្សក្នុងពេលប្រឡងទេ។ វាងាយស្រួលសម្រាប់សិស្សអនឡាញក្នុងការចែករំលែកចម្លើយដោយដឹងថាគ្មាននរណាម្នាក់មើលទេ។ **ទាមទារការលើកទឹកចិត្តខ្លួនឯង និងជំនាញគ្រប់គ្រងពេលវេលាត្រឹមត្រូវ** សិស្សត្រូវមានមូលដ្ឋានដោយខ្លួនឯងនៅក្នុងការរៀនតាមអ៊ីនធើណិត។ អ្នកត្រូវជំរុញចិត្តខ្លួនឯងឱ្យខិតខំសិក្សា កត់ចំណាំនិងប្រមូលព័ត៌មានបន្ថែមទៀត។ អ្នកក៏គួរតែគ្រប់គ្រងពេលវេលារបស់អ្នកឱ្យបានល្អដោយរៀនពីរបៀបសិក្សាពេលកំពុងធ្វើកិច្ចការផ្សេងៗ ដូចជាការងារផ្ទះ ឬរកប្រាក់ក្រៅម៉ោងជាដើម។ ម្យ៉ាងវិញទៀតចំពោះសិស្សដែលងាយ នឹងទទួលរងនូវជំងឺឆ្លងពីមនុស្សជុំវិញខ្លួនមានជម្រើសក្នុងការសិក្សាតាមរយៈ Online វាជាលក្ខណៈពិសេសមួយដែលផ្តល់ឱ្យនិស្សិតមួយចំនួនដែលមានសុខភាពខ្សោយងាយក្នុងការឆ្លងជំងឺផ្សេងៗពីមជ្ឈដ្ឋានជុំវិញខ្លួន។

## ៣.៣ សារៈសំខាន់នៃការសិក្សាពីចម្ងាយនៃកម្រិតឧត្តមសិក្សា

សារៈសំខាន់នៃការសិក្សាពីចម្ងាយមានដូចខាងក្រោម៖

### ៣.៣.១ លទ្ធភាពសមរម្យ

ហេតុផលមួយដែលធ្វើឱ្យការរៀនតាមអ៊ីនធើណិត បានកើតឡើងតាំងពីឆ្នាំ២០០៨ហូតមក។ ការរៀនតាមអ៊ីនធើណិតធ្វើឱ្យចំណាយតិច មានភាពងាយស្រួល នរណាៗក៏អាចសិក្សាបានដែរ។ វាជាកម្មវិធីថ្នាក់រៀនមួយដែលធ្វើឱ្យចំណេញភាគីទាំងសងខាងដូចជា គ្រូមិនចាំបាច់ត្រូវការថ្នាក់រៀន សម្ភារជាដើម។ ហេតុនេះហើយវាធ្វើឱ្យសិស្សអាចទទួលបានការសិក្សាគ្រប់ទីកន្លែង នឹងគ្រប់ពេលវេលា។

### ៣.៣.២ ចំណេញពេលវេលា

ប្រសិនបើអ្នកជ្រើសរើសរៀនតាមអនឡាញ អ្នកនឹងចំណេញពេលទៅសាលា ឬទៅធ្វើការ ប៉ុន្តែចាប់តាំងពីមានការផ្លាស់ប្តូរការសិក្សាតាមអ៊ីនធើណិតមក អ្នកនឹងចំណេញពេលវេលាទាំងអស់នេះយ៉ាងស្រួល។ ថ្វីត្បិតតែពួកគាត់មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀនដោយផ្ទាល់ក៏ដោយ ក៏ពួកគាត់អាចរៀនបានដែរ គឺតាមរយៈការសិក្សាពីចម្ងាយ ហើយនឹងទទួលបានចំណេះដឹងថ្មីៗ។

### ៣.៣.៣ ចំណេញទីកន្លែងសិក្សា

ចំពោះការសិក្សាតាមប្រព័ន្ធអ៊ីនធើណិត វាមិនតម្រូវឱ្យអ្នកនៅថ្នាក់រៀនមួយកន្លែងដូចមុនទេ។ អ្នកអាចរៀននៅទីណាក៏បានដែរ ឱ្យតែកន្លែងនោះមានល្បឿនអ៊ីនធើណិតដើរលឿនល្មមសម្រាប់ការប្រាស្រ័យទាក់ទងគ្នាទៅបានហើយ។

**៣.៣.៤ កាត់បន្ថយហានិភ័យនៃការឆ្លងជំងឺផ្សេងៗ**

ជាការពិតណាស់ ការសិក្សាតាមប្រព័ន្ធអ៊ីនធើណិតពិតជារឿងដ៏ល្អស្រាប់សិស្ស នឹងគ្រូគ្រប់រូប។ ការសិក្សាបែបនេះធ្វើឱ្យមានគម្លាតសង្គមដែលភាសាអង់គ្លេសហៅថា Social Distance បានមួយកម្រិត។ ដូច្នេះ រវាងគ្រូ និងសិស្សនៅតែអាចដំណើរការសិក្សាបានធម្មតាដោយពុំមានការព្រួយបារម្ភអ្វីឡើយ។

**៣.៣.៥ ពង្រីកចំណេះដឹងថ្មីៗ**

ខណៈពេលរៀនតាមអ៊ីនធើណិត អ្នកមិនបានជួបមុខលោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់ផ្ទាល់នោះទេ ហេតុនេះហើយ អ្នកអាចនឹងឱកាសឆ្ងល់សួរបានច្រើន។ ប្រសិនបើ អ្នកមិនយល់ត្រង់ចំណុចណាមួយនៃមេរៀន អ្នកអាចសុំគ្រូរបស់អ្នកឱ្យជួយពន្យល់បន្ថែមបាន។ លើសពីនេះពួកគាត់ទទួលបាននូវចំណេះដឹងខាងផ្នែកបច្ចេកវិទ្យាថ្មីសម្រាប់ពួកគាត់យកទៅប្រើប្រាស់ក្នុងការសិក្សា មានការអភិវឌ្ឍន៍ខ្លួនយ៉ាងឆាប់រហ័ស មានសកម្មភាពក្នុងការរៀន កត់ត្រា រហ័សរហួន ចេះបត់បែនតាមកាលៈទេសៈ នឹងធ្វើឱ្យខ្លួនកាន់តែមានវិន័យល្អ។

**៣.៣.៦ ការសហការគ្នាក្នុងការរៀនសូត្រ**

អ្នកសិក្សានាពេលបច្ចុប្បន្ននេះជាច្រើនបានទទួល នឹងការចែករំលែកខ្លឹមសារមេរៀន នឹងការស្រាវជ្រាវផ្សេងៗនៅលើអ៊ីនធើណិត។ ក្នុងនាមជាអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ពួកគេត្រូវបានប្រើអ៊ីនធើណិតដែលមានការសហការបានល្អ។

**៣.៣.៧ ធ្វើឱ្យប្រសើរឡើងនូវអក្ខរកម្មឌីជីថល**

យើងទាំងអស់គ្នា ត្រូវតែចេះអក្សរឌីជីថលក្នុងយុគសម័យបច្ចេកវិទ្យាបច្ចុប្បន្ន។ អក្ខរកម្មឌីជីថលមានន័យថា អាចប្រើប្រាស់បច្ចេកវិទ្យាដើម្បីស្វែងរក នឹងចែករំលែកព័ត៌មាន។ វាជាជំនាញជីវិតដ៏សំខាន់ ក៏ដូចជាតម្រូវការជាមុនសម្រាប់ការងារជាច្រើន សូម្បីតែការដាក់ពាក្យសុំការងារក៏ទំនងជារួមបញ្ចូលបច្ចេកវិទ្យាផងដែរ។

**៣.៣.៨ ចូលរួមលើកកម្ពស់លើវិស័យបច្ចេកវិទ្យា**

នាពេលបច្ចុប្បន្ននេះ មានការជឿនលឿនយ៉ាងខ្លាំងខាងបច្ចេកវិទ្យាទំនើបៗ ដែលធ្វើឱ្យនិស្សិតគ្រប់ត្រូវចេះប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនេះ ហើយក៏ជាភាពងាយស្រួលដល់ការសិក្សាបានច្រើនជាងមុនដែរ ធ្វើឱ្យនិស្សិតចេះប្រើយ៉ាងស្ទាត់ជំនាញលើបច្ចេកវិទ្យាទាំងនេះ ជាពិសេស ជួយអភិវឌ្ឍដល់វិស័យបច្ចេកវិទ្យានេះឱ្យកាន់តែរីកចម្រើនជាលំដាប់។

**៣.៣.៩ កាត់បន្ថយពេលវេលាពីការស្ទះចរាចរណ៍**

សិស្សនិស្សិតតែងតែមានផលលំបាកក្នុងការធ្វើដំណើរទៅសាលារៀន ព្រោះមានការកកស្ទះនៅតាមផ្លូវមកសាលាធ្វើឱ្យពួកមករៀនមិនទាន់។ តែពេលបានពីចម្ងាយធ្វើឱ្យងាយស្រួលមិនចាំបាច់ចំណាយពេលនឹងការស្ទះចរាចរណ៍នោះទេ។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយទៅលើការសិក្សាពីចម្ងាយ ជាការវិភាគដែលមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែងពីការសិក្សាតាមប្រព័ន្ធឌីជីថល ដើម្បីឱ្យអ្នកសិក្សាមានភាពងាយស្រួលក្នុងការរៀនសូត្រ និងស្រាវជ្រាវ។ បន្ទាប់ពីធ្វើការស្រាវជ្រាវ និងអនុវត្តន៍ផ្ទាល់លើកម្មវិធីសិក្សានេះ បានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ការវិភាគទៅលើចំណុចខ្លាំងមានដូចខាងក្រោម៖

- **ការរៀនតាមពេលវេលា៖** អ្នកអាចរៀននៅពេលណាក៏បាន មានន័យថានៅពេលដែលអ្នកទំនេរពីធ្វើការ ឬកិច្ចការងារផ្ទះផ្សេងៗ។
- **ចំណេញពេលវេលា៖** ប្រសិនបើអ្នកជ្រើសរើសរៀនតាមអនឡាញអ្នក នឹងចំណេញពេលទៅសាលា ឬទៅធ្វើការ ប៉ុន្តែ ចាប់តាំងពីមានការផ្លាស់ប្តូរការសិក្សាតាមអ៊ីនធើណិតមកអ្នកនឹងចំណេញពេលវេលាទាំងអស់នេះយ៉ាងស្រួល។
- **ការសិក្សាមានភាពបត់បែន៖** ការអប់រំតាមអ៊ីនធើណិត អនុញ្ញាតឱ្យបុគ្គលម្នាក់ៗសិក្សាតាមជំហាន នឹងតាមកាលវិភាគរបស់ពួកគេផ្ទាល់។ ថ្នាក់រៀនបែបឌីជីថល អាចចូលមើលបានគ្រប់ទីកន្លែង នឹងគ្រប់ពេលវេលា។ នេះ គឺជាផលប្រយោជន៍ដ៏សំខាន់សម្រាប់ការរៀនតាមអនឡាញ នៅក្នុងពិភពលោកដែលពោរពេញទៅដោយភាពមមាញឹកជាច្រើន។ កម្មវិធីសិក្សាតាមអនឡាញនេះ មិនតម្រូវឱ្យសិស្សចាំបាច់ត្រូវតែចូលរៀនក្នុងថ្នាក់ដែលអាចរំខានដល់កាតព្វកិច្ចគ្រួសារ នឹងអាជីពឡើយ។
- **ការសិក្សាលក្ខណៈបុគ្គល៖** ការរៀនសូត្រតាមអនឡាញអាចជួយឱ្យសិស្សទទួលយកចំណុចខ្លាំងរបស់ពួកគេ និងកាត់បន្ថយចំណុចខ្សោយរបស់ពួកគេបាន។ និស្សិតដែលពូកែអៀន មិនចាំបាច់ព្រួយបារម្ភអំពីការដាក់ទណ្ឌកម្មចំពោះការដែលមិននិយាយស្តីឡើយ។ ថ្នាក់រៀនអនឡាញអាចជួយកាត់បន្ថយការបំភិតបំភ័យដែលបុគ្គលម្នាក់ៗអាចជួបប្រទះនៅពេលនិយាយស្តីនៅក្នុងថ្នាក់។
- **ផ្តល់ឱកាសសម្រាប់សិស្សគ្រប់វ័យនិងគ្រប់តម្រូវការ៖** ជាក់ស្តែងសិស្ស និស្សិតដែលមានកូន ឬឪពុកម្តាយចាស់ជរាក្នុងបន្ទុកនឹងមានការពិបាកក្នុងការចូលរៀននៅក្នុងថ្នាក់។ វគ្គសិក្សតាមអ៊ីនធើណិតផ្តល់ជូននូវជម្រើសដ៏អស្ចារ្យសម្រាប់អ្នកដែលមានកាតព្វកិច្ចបែបនេះ។
- **ចេះប្រើប្រាស់ប្រព័ន្ធឌីជីថលបានច្រើនក្នុងការស្វែងរកឯកសារ៖** គឺជាមធ្យោបាយងាយស្រួលដែលជួយដល់និស្សិតក្នុងការរៀនតាម Online និងការស្រាវជ្រាវនូវទិន្នន័យផ្សេងៗ។
- **កាត់បន្ថយហានិភ័យគ្រោះថ្នាក់ដែលកើតឡើងពេលធ្វើដំណើរដោយថាហេតុ និងជំងឺផ្សេងៗ៖** ការសិក្សាពីចម្ងាយជួយសម្រួលដល់និស្សិតដែលមានផ្ទះនៅឆ្ងាយ ឬនៅតំបន់ដាច់ស្រយាលការធ្វើដំណើរមករៀនដែលជាហេតុធ្វើឱ្យពួកគាត់ជួបនូវគ្រោះថ្នាក់នៅតាមផ្លូវ ឬនៅបន្ទប់ជួល។
- **ការបង្កើនជំនាញបច្ចេកវិទ្យា៖** ការរៀនតាមអនឡាញ អាចជួយអ្នកបង្កើនជំនាញបច្ចេកវិទ្យាដែលមានប្រយោជន៍សម្រាប់ការងារនាពេលអនាគត។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជាការសិក្សាពីចម្ងាយ ទទួលបានភាពរីកចម្រើនលើវិស័យអប់រំយ៉ាងក៏ដោយ ក៏ការសិក្សានូវពុំទាន់ទទួលបានភាពជោគជ័យទាំងស្រុងនៅឡើយទេ។ ទន្ទឹម នឹងចំណុចខ្លាំងដូចដែលបានរៀបរាប់ខាងលើនេះ ការសិក្សាពីចម្ងាយក៏មានចំណុចខ្វះខាតមួយចំនួនតូចផងដែរមានដូចជា៖

- **ការសិក្សាតាមអនឡាញងាយមានបញ្ហាបច្ចេកទេស នឹងអ៊ីនធើណិត៖** ជាការពិតណាស់ការសិក្សាតាមអ៊ីនធើណិត អាចជួបបញ្ហាដូចជា អ៊ីនធើណិត ឬអាចដាច់ចរន្តអគ្គិសនី និងបញ្ហាផ្សេងៗ។ អ្នកខ្លះនៅក្នុងតំបន់ដែលមានតភ្ជាប់អ៊ីនធើណិតលឿន អ្នកខ្លះមានការចូលប្រើអ៊ីនធើណិតនូវមានកម្រិតនៅឡើយ។
- **ប្រសិទ្ធភាពនៃការគ្រប់គ្រងពេលវេលា នឹងវិន័យនូវមានកម្រិត៖** អ្នកក៏គួរតែគ្រប់គ្រងពេលវេលារបស់អ្នកឱ្យបានល្អដោយរៀនពីរបៀបសិក្សាពេលកំពុងធ្វើកិច្ចការផ្សេងៗ។ ការរៀនតាមអ៊ីនធើណិតធ្វើឱ្យសិស្សងាយស្រួលក្នុងការចែករំលែកចម្លើយគ្នាទៅវិញទៅមក ហើយមានសិស្សមួយចំនួនចូលរៀនគ្រាន់តែយកវត្តមានតែប៉ុណ្ណោះ។
- **ទាមទារការលើកទឹកចិត្តខ្លួនឯង និងបញ្ហានៅជុំវិញ៖** អ្នកត្រូវជំរុញចិត្តខ្លួនឯងឱ្យខិតខំសិក្សា កត់ចំណាំ នឹងប្រមូលព័ត៌មានបន្ថែមទៀត។ នៅក្នុងការសិក្សានេះផងដែរក៏មានការរំខានច្រើនពីតំបន់ដែលនៅជុំវិញយើង។
- **ខ្វះខាតការអនុវត្តន៍ជាក់ស្តែង៖** មុខវិជ្ជាដែលត្រូវការអនុវត្តន៍ ជាក់ស្តែងអាចមានការលំបាកក្នុងការរៀនតាមអនឡាញ។
- **ការខ្វះការទំនាក់ទំនងផ្ទាល់មុខ៖** អ្នកអាចមានអារម្មណ៍ថាខ្វះការទំនាក់ទំនងផ្ទាល់មុខជាមួយគ្រូបង្រៀន នឹងមិត្តរួមថ្នាក់។ រងសម្ពាធដោយសារស្នាក់នៅតែក្នុងផ្ទះមិនសូវបានចេញក្រៅស្រូបយកខ្យល់អាកាសដូចនៅសាលាដែលមានទីធ្លាធំ ហើយម្យ៉ាងវិញទៀតគឺមិនអាចជួបមិត្តភក្តិដូចការរៀនក្នុងថ្នាក់។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវរួចមកទាក់ទងទៅ នឹងប្រធានបទ "សារៈសំខាន់នៃការសិក្សាពីចម្ងាយ" មកយើងឃើញថា ការសិក្សាពីចម្ងាយមានការរៀបចំរបៀបបែបបទ នៃការសិក្សាសមស្របទៅ នឹងតម្រូវការសិក្សារបស់សិស្សគ្រប់ៗរូបប្រកបទៅដោយស្តង់ដាជាមួយ នឹងប្រព័ន្ធអប់រំគ្រប់គ្រងល្អចាប់ពីថ្នាក់លើរហូតដល់បុគ្គលិកអប់រំគ្រប់ជាន់ថ្នាក់។ ជាពិសេសការសិក្សាពីចម្ងាយនេះផងដែរ តាមរយៈការដកបទពិសោធន៍នៃការស្រាវជ្រាវក្នុងអំឡុងឆ្នាំ២០២៣ នេះដែរ យើងសង្កេតឃើញ មានកំណើននៃការចូលរៀនពីចម្ងាយជាច្រើន ដែលការរៀនបែបនេះ ធ្វើឱ្យពួកគាត់ទទួលបាននូវចំណេះដឹងថ្មីៗ ចេះគ្រប់គ្រងពេលវេលា មិនតែប៉ុណ្ណោះ ជួយកាត់បន្ថយនូវការចំណាយបានមួយកម្រិតទៀតផង។ លើសពីនេះ កាត់បន្ថយនូវហានិភ័យនៃការឆ្លងជំងឺផ្សេងៗ ធ្វើឱ្យពួកគាត់មិនមានការបារម្មណ៍ខ្លាចឆ្លងជំងឺទេ ម្យ៉ាងវិញទៀត ជួយពង្រីកនូវចំណេះ ជំនាញរបស់ពួកគាត់ឱ្យកាន់តែខ្លាំងជាមុន។ ទន្ទឹម នឹងគុណសម្បត្តិនេះដែរ ការសិក្សាពីចម្ងាយនៅមានចំណុចខ្វះខាតមួយចំនួន ដែលតម្រូវអោយក្រសួងអប់រំត្រូវធ្វើការកែលម្អបន្ថែមទៀត និងដោះស្រាយទៅលើបញ្ហាមានភាពរអាក់រអួលក្នុងការសិក្សាពាក់ព័ន្ធទៅលើសេវាទូរស័ព្ទនៅពេលរៀន។ មុននឹងទទួលបាននូវ លក្ខណៈសម្បត្តិដែលបានរៀបរាប់ខាងលើក៏មានបញ្ហាមួយចំនួនដែលធ្វើឱ្យពួកគាត់ជួបប្រទះដែលដូចជា បញ្ហាគ្រួសារ មធ្យោបាយ ឬយានជំនិះនិងខ្លួនឯងជាដើម។ ទោះបីជាមានបញ្ហាទាំងនេះ ក៏ដោយក៏ពួកគាត់នៅតែបន្តការសិក្សាបានទៅយ៉ាងរលូនដែរ។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវអំពីប្រធានបទខាងលើ បានបង្ហាញឱ្យឃើញពីចំណុចល្អជាច្រើនតាមរយៈការសិក្សាពីចម្ងាយហើយក៏មាននូវចំណុចខ្វះខាតខ្លះៗផងដែរ។ ក្រុមយើងខ្ញុំសូមផ្តល់ជាមតិយោបល់និងអនុសាសន៍មួយចំនួនក្នុងន័យស្ថាបនាកែលំអរនៅចំណុះខ្វះខាតទាំងនោះ ដើម្បីឱ្យការសិក្សាពីចម្ងាយទទួលបាននូវភាពងាយស្រួលជាងមុនសម្រាប់អ្នកសិក្សាទាំងអស់ នឹងមានការរីចម្រើនជាលំដាប់។

- **ការសិក្សាតាមអនឡាញងាយមានបញ្ហាបច្ចេកទេស នឹងអ៊ីនធើណិត៖** ជាការពិតណាស់ការសិក្សាតាមអ៊ីនធើណិត អាចជួបបញ្ហាដូចជា អ៊ីនធើណិត ឬអាចដាច់ចរន្តអគ្គិសនី និងបញ្ហាផ្សេងៗ។ ដូចនេះ ដើម្បីឱ្យការសិក្សាតាមអនឡាញទទួលបានប្រសិទ្ធភាពខ្ពស់ និស្សិតគួរគប្បីមានកាតទូរស័ព្ទដើម្បីជំនួសពេលដាច់អ៊ីនធើណិត នឹងមាននូវឧបករណ៍អេឡិចត្រូនិច ដើម្បីជំនួសពេលដាច់ចរន្តអគ្គិសនី។ ដើម្បីឱ្យអ៊ីនធើណិតមានដំណើរការល្អ នឹងសម្រួលដល់ការសិក្សាឱ្យកាន់តែរលូននិស្សិតគួរគប្បីស្វែងរកកន្លែងដែលមានអ៊ីនធើណិតគ្រប់គ្រាន់។
- **ប្រសិទ្ធភាពនៃការគ្រប់គ្រងពេលវេលា នឹងវិន័យនូវមានកម្រិត៖** ការរៀនតាមអនឡាញ ធ្វើឱ្យសិស្សងាយស្រួលក្នុងការបែងចែកចម្លើយគ្នាទៅវិញទៅមក ដែលជាហេតុធ្វើឱ្យគ្រូពិបាកគ្រប់គ្រងសិស្ស។ ដូចនេះ សាលាគួរគប្បីបង្កើតឱ្យមានការប្រឡងតាមរយៈអនឡាញដូចជាតាមកម្មវិធី Zoomជាដើម។

- **ទាមទារការលើកទឹកចិត្តខ្លួនឯង និងបញ្ហានៅជុំវិញ៖** ដើម្បីឱ្យការសិក្សាពីចម្ងាយទៅបានយ៉ាងល្អ យើងគួរចេះលើកទឹកចិត្តខ្លួន ក្នុងការរៀនឱ្យមានវិន័យច្បាស់លាស់ នឹងត្រូវចេះដោះស្រាយរាល់បញ្ហាដែលធ្វើឱ្យពិបាកក្នុងការរៀន។
- **ខ្វះខាតការអនុវត្តន៍ជាក់ស្តែង៖** មុខវិជ្ជាដែលត្រូវការអនុវត្តន៍ជាក់ស្តែង អាចមានការលំបាកក្នុងការរៀនតាមអនឡាញ។ ដូចនេះ សាលាគួរគប្បីមានកិច្ចការស្រាវជ្រាវឱ្យនិស្សិតអនុវត្តន៍ដោយខ្លួនឯងបានផងដែរ នឹងឱ្យអាណាព្យាបាលចូលរួមក្នុងការត្រួតពិនិត្យសៀវភៅមេរៀនកូនជាដើម។
- **ការខ្វះការទំនាក់ទំនងផ្ទាល់មុខ៖** អ្នកអាចមានអារម្មណ៍ថា ខ្វះការទំនាក់ទំនងផ្ទាល់មុខជាមួយគ្រូបង្រៀន នឹងមិត្តរួមថ្នាក់។ លោកគ្រូ អ្នកគ្រូបង្កើតឱ្យមានកិច្ចការជាក្រុមដើម្បីឱ្យនិស្សិតមានភាពស្និទ្ធស្នាល។

# ឯកសារយោង

# ឯកសារយោង


1. វិស័យអប់រំនៅកម្ពុជា-វិគីភីឌា (wikipedia.org)
2. វិធីសាស្ត្រក្នុងការសិក្សាឲ្យមានប្រសិទ្ធភាព | ខ្មែរអ្នកអប់រំ (khmereducator.org)
3. យោង៖ទស្សនាវដ្ដីវិទ្យាសាស្ត្រ សេដ្ឋកិច្ច 4.0
4. ការអប់រំកម្រិតឧត្តមសិក្សា Open Development Cambodia (ODC)ដកស្រង់ចេញពី(ក្រសួងអប់រំ យុវជន និងកីឡា, «គោលនយោបាយ ស្ដីពី ចក្ខុវិស័យឧត្តមសិក្សា ២០៣០,»ទំព័រ២, ខែមេសា ឆ្នាំ ២០១៤, បានចូលអានខែមេសា ឆ្នាំ២០២២)
5. ការអប់រំកម្រិតឧត្តមសិក្សា Open Development Cambodia (ODC)ដកស្រង់ចេញពី(ក្រសួងអប់រំ យុវជន និងកីឡា, «ផែនទីបង្ហាញផ្លូវនៃការអប់រំឆ្នាំកម្ពុជា២០៣០៖ គោលដៅប្រកបដោយចីរភាពទី ៤,» ទំព័រ ១៥, ខែកុម្ភៈ ២០១៩, បានចូលអានខែមេសា ឆ្នាំ២០២២)
6. ការអប់រំកម្រិតឧត្តមសិក្សា Open Development Cambodia (ODC)ដកស្រង់ចេញពី(ក្រសួងអប់រំ យុវជន និងកីឡា, «សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៩-២០២០ និងលើកទិសដៅ ឆ្នាំសិក្សា២០២០-២០២១,» ទំព័រ ៨៦, ខែមេសា ឆ្នាំ២០២១, បានចូលអានខែមេសា ឆ្នាំ២០២២)
7. ttps://km.wikipedia.org/wiki/វិស័យអប់រំនៅកម្ពុជា#ប្រវត្តិ
8. https://mengkorngdata.files.wordpress.com/2016/01/...
9. https://km.wikipedia.org/wiki/%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%A2%E1%9E%94%E1%9F%8B%E1%9E%9A%E1%9F%86
10. https://ahaslides.com/km/blog/distance-learning/
11. https://npn.news/post/55962/2928
12. https://videoslearning.com/1-1002/
13. https://www.sangapac.com/dictionary/sa/5997
14. https://thmeythmey.com/?page=detail&id=64754
15. https://videoslearning.com/1-2367/
16. https://newsroomcambodia.com/kh/2020/09/08/youth-opinions-about-online-studies/
17. https://www.facebook.com/photo.php?fbid=4022466521183895&id=446300842133832&set=a.446310415466208
18. https://elearning.moeys.gov.kh/k4/social/_3.html

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ



សកម្មភាពគ្រូបង្រៀនពីចម្ងាយ



សកម្មភាពសិស្សកំពុងសិក្សានៅផ្ទះ



